ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


១៧-៦-២០១១ -ព្រះរាជក្រម នស/រកម/០៦១១/០១១ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពី របប ហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៤៧៧៤


### ២. ព្រះរាជក្រឹត្យ


២៣-៥-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៥១១/៤៦០ ស្តីពី ការតែងតាំងលោក **ឈុន លឹម** ជា ឧកញ៉ា ៤៧៩៤

០២-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥១៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីសង្ឃ សប្បុរសជន និង មន្ត្រីរាជការ ចំនួន ០៧ រូប ៤៧៩៥

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥១៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ទីប្រឹក្សា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និង សប្បុរសជន ចំនួន ១០៨ រូប ៤៧៩៦

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២០ ស្តីពី ការតែងតាំងឯកឧត្តម **មាស គឹមហេង** ជា ទីប្រឹក្សាឯកឧត្តម **ហោ ណាំបូរ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ ៤៧៩៩

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ១០ រូប ៤៨០០

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ទីប្រឹក្សា សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ចំនួន ១៨ រូប ៤៨០១

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ០៥ រូប ៤៨០២

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿង ឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចំនួន ០៥ រូប ៤៨០៣

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២៥ ស្តីពី ការតែងតាំងឯកឧត្តម **ខេង ច័ន្ទា** ជា ឧកញ៉ា ៤៨០៤

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ប្រគេនចំពោះ ព្រះភិក្ខុ ខណ្ឌ សម្បត្តិ ព្រះចៅអធិការវត្ត បុទុមសីរីសែនមង្គល ៤៨០៥

០៣-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥២៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ១៥ រូប ៤៨០៦

០៤-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៥៣០ ស្តីពី ការបន្ថយរយៈពេលទទួលរងទោស និង លើកលែងទោស ឱ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ចំនួន ១២៧ នាក់ ៤៨០៧

## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ

១៦-៦-២០១១ -អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពី ការធ្វើវិសោធនកម្មលើអនុក្រឹត្យ អនុបយោគទីតាំងទីស្នាក់ការក្រុមហ៊ុន កាំមីនតែល ៤៨២៥

១៧-៦-២០១១ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៤៨២៧

១៧-៦-២០១១ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពី ការបញ្ចូលមណ្ឌលសភាពាណិជ្ជកម្ម ខេត្តកំពត ខេត្តតាកែវ និង ខេត្តកែប ជាមណ្ឌលសភាពាណិជ្ជកម្មតែមួយ ៤៨២៩

១៧-៦-២០១១ -អនុក្រឹត្យលេខ ១២២ អនក្រ.បក ស្តីពី ការបញ្ចូលមណ្ឌលសភាពាណិជ្ជកម្ម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និង ខេត្តរតនគិរី ជាមណ្ឌលសភាពាណិជ្ជកម្មតែមួយ ៤៨៣១

១០-៦-២០១១ -អនុក្រឹត្យលេខ ៦៩០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៨៣៣

១០-៦-២០១១ -អនុក្រឹត្យលេខ ៦៩១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៤៨៣៤

១០-៦-២០១១ -អនុក្រឹត្យលេខ ៦៩២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិ នាយទាហាន ៤៨៣៥

១០-៦-២០១១ -អនុក្រឹត្យលេខ ៦៩៣ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៤៨៣៧

១០-៦-២០១១ -អនុក្រឹត្យលេខ ៦៩៤ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិ នាយទាហាន ៤៨៣៩

១៣-៦-២០១១ -អនុក្រឹត្យលេខ ៦៩៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិ នាយនគរបាលជាតិ ៤៨៤១

១៣-៦-២០១១ -អនុក្រឹត្យលេខ ៦៩៦ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិ និង តែងតាំងមន្ត្រីរាជការ ៤៨៤២

១៣-៦-២០១១ -អនុក្រឹត្យលេខ ៦៩៧ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរសក្តិ នាយនគរបាលជាតិ ៤៨៤៣

១៣-៦-២០១១ -អនុក្រឹត្យលេខ ៦៩៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៨៤៤

១៣-៦-២០១១ -អនុក្រឹត្យលេខ ៦៩៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៨៤៥

១៣-៦-២០១១ -អនុក្រឹត្យលេខ ៧០០ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៤៨៤៧

១៣-៦-២០១១ -អនុក្រឹត្យលេខ ៧០១ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៤៨៤៨

១៣-៦-២០១១ -អនុក្រឹត្យលេខ ៧០២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៨៤៩

## ២. សេចក្តីសំរេច

០៨-៦-២០១១ -សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពី ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី ១៦ និង កិច្ចប្រជុំពាក់ព័ន្ធ ៤៨៥០

០៨-៦-២០១១ -សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពី ការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ៤៨៥២

# III. ការិយាល័យក្រសួង

## ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៣-៦-២០១១ -ប្រកាសលេខ ៣៨៣ សហវ.អពដ.ប្រក ស្តីពី ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ ២០១១ ៤៨៥៤

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

៣០-៥-២០១១ -ប្រកាសលេខ ៤៦១ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាញ្ញទីរ៉ង ថៃកស្វាយ ខប បង្កើតរោងចក្រ ផលិតសម្បៀកបំពាក់ ៤៨៦៤

៣០-៥-២០១១ -ប្រកាសលេខ ៤៦២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន តុន យុន ថិចថាយ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៤៨៦៨

## ៣. គណៈកម្មការមូលបត្រកម្ពុជា

០៣-៥-២០១១ -ប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក ស្តីពី ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ ៤៨៧២

## ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៤-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៦៥៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.ខេ.វេ.ត្រេឌីង** ៤៨៨៤

០៤-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៦៥៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន ម៉េរីយនីខល អេន អេឡិចត្រូនិខល ប្រដាក់ អ៊ីមផត អិចផត** ៤៨៨៦

០៤-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៦៥៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិល 2 ខេ អ៊ិនធើណេសិនណល** ៤៨៨៨

០៤-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៦៦០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃីន ផាតនើរ (ខនស្ត្រាក់សិន)** ៤៨៥០

០៤-៨-២០១០ -លិខិតបញ្ជាក់លេខ ៣៦៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូខ ហ្វុខ អ៊ិនដាសស្ទ្រី ខបភើរេសិន អិលធីឌី** ៤៨៥២

# ព្រះរាជក្រម

នស/រកម/០៦១១/០១១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# របបហិរញ្ញវត្ថុ
# និងការគ្រប់គ្រងទ្រព្យសម្បត្តិ
# របស់
# រដ្ឋបាលថ្នាក់ក្រោមជាតិ

ROYAUME DU CAMBODGE

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់អំពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងបង្កើតនូវប្រភពធនធានហិរញ្ញវត្ថុ ដើម្បីឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានលទ្ធភាពសមស្រប ក្នុងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាព និង លើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនមានវិសាលភាពអនុវត្តចំពោះរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់ទេ លើកលែងតែមានបទប្បញ្ញត្តិដែលចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ហៅកាត់ថា "រដ្ឋបាលថ្នាក់ក្រោមជាតិ" គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានទ្រព្យសម្បត្តិ ធនធានហិរញ្ញវត្ថុ និង ថវិកាផ្ទាល់របស់ខ្លួន ។

នៅក្នុងក្របខ័ណ្ឌនៃច្បាប់នេះ ពាក្យថា "រដ្ឋបាលថ្នាក់ក្រោមជាតិ" គឺសំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥.-**

ក្នុងការគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុ និង ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមគោលការណ៍ជាមូលដ្ឋាន ដូចមានចែងនៅក្នុង មាត្រា ២ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

# ជំពូកទី ២
# សមត្ថកិច្ច និង ការគ្រប់គ្រងហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៦.-**

ក្រុមប្រឹក្សានីមួយៗត្រូវធ្វើជាតំណាង និង ធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋ និងត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុសាធារណៈ ដើម្បីជំរុញដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយចីរភាពនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និង ចាត់ចែងកិច្ចការហិរញ្ញវត្ថុឲ្យមានប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និង ចំពោះរាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការ ។

**មាត្រា ៧.-**

ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវទទួលខុសត្រូវ ដូចខាងក្រោម :

- ពិនិត្យ និង អនុម័តផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- ពិនិត្យ និង អនុម័តផែនការយុទ្ធសាស្ត្រថវិកា និង គម្រោងថវិកាប្រចាំឆ្នាំដែលដាក់ជូនដោយអភិបាល និង មានសិទ្ធិក្នុងការផ្លាស់ប្តូរថវិកា ក្នុងករណីការផ្លាស់ប្តូរមិនរំលោភច្បាប់ បទបញ្ញា ឬ គោលការណ៍នៃការរៀបចំថវិកា
- ពិនិត្យ និង អនុម័តការកែសម្រួលថវិកាទៅតាមសំណើរបស់អភិបាល
- ពិនិត្យ និង អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យ និង អនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមវិធាន និង បទបញ្ញាជាធរមាន
- តាមដានត្រួតពិនិត្យការអនុវត្តហិរញ្ញវត្ថុ និង ថវិការបស់អភិបាល
- ពិនិត្យ និង អនុម័តកិច្ចសន្យាកិច្ចព្រមព្រៀងដែលបង្កើតការសន្យាហិរញ្ញវត្ថុ ឬ អត្ថប្រយោជន៍លើសពីឆ្នាំថវិកាកំពុងអនុវត្ត ។

**មាត្រា ៨.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីជាតំណាងក្រសួងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។ នៅក្នុងវិស័យ

ហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ជាអ្នកប្រតិបត្តិផ្ទាល់តាមដីកា និង សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្នុងការអនុវត្តច្បាប់នេះ។

**មាត្រា ៩.–**

អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវចំពោះកិច្ចការដូចខាងក្រោម :

- រៀបចំផែនការអភិវឌ្ឍ កម្មវិធីវិនិយោគបីឆ្នាំរំកិល និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ
- អនុវត្តផែនការសកម្មភាព និង គម្រោងថវិកាប្រចាំឆ្នាំ ដែលក្រុមប្រឹក្សាបានអនុម័តស្របទៅតាមវិធាននិងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាធរមាន
- រាយការណ៍ជាទៀងទាត់ជូនក្រុមប្រឹក្សាអំពីការអនុវត្តផែនការសកម្មភាព និង គម្រោងថវិកាប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របាយការណ៍អនុវត្តចំណូលចំណាយថវិកាប្រចាំឆ្នាំ និង របាយការណ៍ផ្សេងៗទៀតដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័តតាមកាលកំណត់
- រាយការណ៍ជាទៀងទាត់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័នពាក់ព័ន្ធអំពីការអនុវត្ត និង ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោយពេលដែលរបាយការណ៍នានាបានអនុម័តដោយក្រុមប្រឹក្សារួចហើយ
- គ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និង ថែរក្សាទ្រព្យសម្បត្តិដែលថ្នាក់ជាតិប្រគល់ឲ្យកាន់កាប់នៅក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញាជាធរមាន ។

**មាត្រា ១០.–**

ប្រធានហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ មានតួនាទីជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការជួយក្រុមប្រឹក្សា និង អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឲ្យសម្រេចបាននូវរាល់ការកិច្ចដូចបានបញ្ជាក់ក្នុង មាត្រា ៧ និង មាត្រា ៩ នៃច្បាប់នេះ ។

ប្រធានហិរញ្ញវត្ថុត្រូវបំពេញតួនាទីខាងលើនេះ ដោយមានការសម្របសម្រួលពីនាយករដ្ឋបាល និង មានកិច្ចសហការជាមួយអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ប្រធានហិរញ្ញវត្ថុនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៅក្រោមសិទ្ធិអំណាចអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ប្រធានហិរញ្ញវត្ថុត្រូវបានតែងតាំងដោយក្រុមប្រឹក្សា បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

បែបបទនៃការជ្រើសរើស តែងតាំង និង ការកំណត់លក្ខណៈសម្បត្តិប្រធានហិរញ្ញវត្ថុត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

ចំពោះវិស័យហិរញ្ញវត្ថុនៅក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិទាំងឡាយក្នុងជំពូកទី ៣ នៃច្បាប់នេះ អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សាគឺជាអាណាប័កដើមខ្សែ ជាអ្នករៀបចំ និង អនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ក្នុងការអនុវត្តថវិកាស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ អភិបាលនៃគណៈអភិបាលក្នុងនាមក្រុមប្រឹក្សាជាអ្នកបញ្ជាចំណូល សន្យាចំណាយ ជម្រះបញ្ជី និង បញ្ជាចំណាយដោយផ្អែកលើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអនុម័ត និង ជាអ្នកគ្រប់គ្រង បង្កើត និងបញ្ឈប់គណនីរដ្ឋបាល។

**មាត្រា ១២.-**

អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរក្នុងការសម្រេចលើថវិកាឲ្យទៅអភិបាលរងណាម្នាក់ ជាអាណាប័កផ្ទេរសិទ្ធិដែលធ្វើសកម្មភាពដោយស្ថិតនៅក្នុងការទទួលខុសត្រូវ និង ត្រួតពិនិត្យរបស់អភិបាល ។ អាណាប័ក និង អាណាប័កផ្ទេរសិទ្ធិត្រូវតម្កល់គំរូហត្ថលេខាជាផ្លូវការដល់គណនេយ្យករសាធារណៈ ។

**មាត្រា ១៣.-**

ខណ្ឌ និង សង្កាត់ចំណុះរាជធានី ត្រូវមានថវិការបស់ខ្លួនស្ថិតនៅក្នុងថវិការបស់រាជធានី ។ អភិបាលខណ្ឌ និង ចៅសង្កាត់របស់រាជធានី ជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលរាជធានីចំពោះថវិការបស់ខ្លួន ។

សង្កាត់ចំណុះក្រុងត្រូវមានថវិការបស់ខ្លួនស្ថិតនៅក្នុងថវិការបស់ក្រុង ។ ចៅសង្កាត់របស់ក្រុងជាអាណាប័កផ្ទេរសិទ្ធិពីអភិបាលក្រុងចំពោះថវិការបស់ខ្លួន ។

ទម្រង់រចនាសម្ព័ន្ធ និង នីតិវិធីនៃការដាក់បញ្ចូលថវិកាខណ្ឌ និង សង្កាត់ ទៅក្នុងថវិការាជធានី និង ថវិកាសង្កាត់ទៅក្នុងថវិកាក្រុង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីបានពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៤.-**

ការកាន់កាប់ប្រាក់កាសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធានាដោយគណនេយ្យករសាធារណៈផ្ទាល់របស់រតនាគារ ដែលទទួលអនុវត្តពីអាណាប័កនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយគោរពយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍ត្រួតពិនិត្យ និង គ្រប់គ្រងគណនេយ្យសាធារណៈជាធរមាន ។

**មាត្រា ១៥.—**

រតនាគារនៅថ្នាក់ក្រោមជាតិ ត្រូវបំពេញមុខងារជាគណនេយ្យករសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវអនុវត្តភារកិច្ចទាំងឡាយ ដូចខាងក្រោម ៖

- ប្រមូលឬទទួលចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ទូទាត់ចំណាយដែលបានចេញអាណត្តិដោយអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រង និងបើកផ្តល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុតាមកាលកំណត់
- ថែរក្សាទុកដាក់រាល់ឯកសារ សក្ខីបត្រ និង បញ្ជីគណនេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា ១៦.—**

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានរតនាគារ ប្រធានសាខាឬស្នាក់ការពន្ធដារដែលបោះទីតាំងនៅថ្នាក់ក្រោមជាតិជាអ្នកទទួលប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជួយដល់ក្រុមប្រឹក្សា និង អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តច្បាប់នេះ ។

## ជំពូកទី ៣
## ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
### ផ្នែកទី ១
### គោលការណ៍គ្រប់គ្រងថវិកា

**មាត្រា ១៧.—**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុ និង ថវិកាសមស្រប ដើម្បីអនុវត្តរាល់មុខងារ ភារកិច្ចសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ គម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ប្រចាំឆ្នាំត្រូវបានគ្រោង និង អនុញ្ញាតនូវប្រភពធនធាន និង បន្ទុកទាំងអស់ដោយត្រូវធានាឲ្យបាននូវតុល្យភាពនៃថវិកា ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**មាត្រា ១៨.—**

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និង អនុម័តប្រចាំឆ្នាំនីមួយៗ ។ ការិយបរិច្ឆេទនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិចាប់ផ្តើមនៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ។

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ និង អនុម័តដោយមានតុល្យភាពពិតប្រាកដរវាង ចំណូល និង ចំណាយទៅតាមទម្រង់ និង ចំណាត់ថ្នាក់ថវិកា ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ១៩.-**

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំ អនុម័ត និង អនុវត្តស្របតាមគោលការណ៍ ដូចខាងក្រោម :

- ត្រូវផ្សព្វផ្សាយព័ត៌មានឲ្យបានពេញលេញអំពីការរៀបចំ និងការអនុម័តថវិកា
- រាល់ចំណូល និងចំណាយទាំងអស់ត្រូវតែជាផ្នែកនៃថវិកាឯកភាពតែមួយគត់
- ថវិកាត្រូវបញ្ចូលចំណូល និងចំណាយទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចំណូលត្រូវប្រមូល និងបង្ហាញជាទឹកប្រាក់សរុបដោយគ្មានការកាត់កងចំណាយណាមួយឡើយ
- គ្មានចំណូលណាមួយត្រូវបានកំណត់សម្រាប់ការចំណាយជាក់លាក់ណាមួយឡើយ លើកលែងតែមានការអនុញ្ញាតដែលកំណត់ដោយបទប្បញ្ញត្តិដោយឡែក
- សរុបគម្រោងចំណាយត្រូវធានាទាំងស្រុងដោយសរុបគម្រោងចំណូល
- គ្មានចំណូល ឬ ចំណាយណាមួយត្រូវប្រមូល ឬ ប្រើប្រាស់ក្រៅពីខ្ទង់ថវិកាដែលបានអនុម័តឡើយ។

**មាត្រា ២០.-**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំ អនុម័ត និង អនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។

ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ត្រូវបញ្ជាក់អំពីការព្យាករណ៍ដែលមានលក្ខណៈប្រាកដប្រជាលើមូលដ្ឋានចំណូលសម្រាប់រយៈពេលមធ្យម និង វិធានដែលចំណូលទាំងនេះត្រូវបានបែងចែកទៅតាមខ្ទង់ចំណាយនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទម្រង់បែបបទសម្រាប់ការរៀបចំ និង ការអនុម័តក្របខ័ណ្ឌចំណាយរយៈពេលមធ្យមត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២១.-**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឲ្យប្រាក់គេខ្ចី បោះផ្សាយសញ្ញាប័ណ្ណ ធ្វើការចុះហត្ថលេខាលិខិតធានា និង ធ្វើទង្វើណាដោយផ្ទាល់ ឬ ដោយប្រយោលដែលអាចនាំឲ្យកើតមាន

នូវបំណុល ឬ បន្ទុកហិរញ្ញវត្ថុផ្សេងទៀតដោយផ្ទាល់ ឬ ដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា បានទេ ។

ចំពោះការទទួលហិរញ្ញប្បទានឥតសំណង រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការឯកភាពជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២២.–**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រប់គ្រង និង ប្រើប្រាស់ថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និង ចំពោះរាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាសេនាធិការ ។

## ផ្នែកទី ២
## បន្ទុក និង ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ២៣.–**

ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :

- ចំណាយប្រតិបត្តិការរដ្ឋបាល
- ចំណាយក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច
- ចំណាយក្នុងការអនុវត្តមុខងារជាជម្រើស និង
- ចំណាយក្នុងការអនុវត្តតួនាទី ភារកិច្ចផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តជាធរមានដទៃទៀត ។

**មាត្រា ២៤.–**

ចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រួមមាន :

- ចំណូលពីប្រភពនៅមូលដ្ឋាន
- ចំណូលពីថ្នាក់ជាតិ
- ចំណូលផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ២៥.–**

ចំណូលពីប្រភពនៅមូលដ្ឋានរួមមាន ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ :

១- ចំណូលសារពើពន្ធនៅមូលដ្ឋានជាចំណូលពន្ធ និង អាករដែលត្រូវបង្កើត និង កំណត់ដោយច្បាប់ក្នុងក្របខ័ណ្ឌច្បាប់ស្ដីពីសារពើពន្ធ ដើម្បីជាគុណប្រយោជន៍ទាំងស្រុងដល់ថវិកា

របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ការបែងចែកប្រភេទ និង សមាមាត្រចំណូលពន្ធ និង អាករនៅមូលដ្ឋានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យ ។

២- ចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានរួមមាន :

- ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កម្រៃសេវា និងចំណូលផ្សេងៗ

- ការបែងចែកចំណូលមិនមែនសារពើពន្ធ នៅមូលដ្ឋានរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និង តារាងតម្លៃអតិបរមាសម្រាប់ការប្រមូលចំណូលពីកម្រៃសេវា និង ចំណូលផ្សេងៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- អំណោយដែលបានមកពីប្រភពខាងក្នុង និង ខាងក្រៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ

- ចំណូលពីប្រភពផ្សេងៗដែលកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ២៦.-**

ប្រភពចំណូលពីថ្នាក់ជាតិ រួមមាន :

- ចំណូលចែករំលែក

- មូលនិធិផ្ទេរពីថវិកាថ្នាក់ជាតិ និង

- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៧.-**

ចំណូលចែករំលែកគឺជាចំណូលដែលត្រូវចែករំលែករវាងថ្នាក់ជាតិ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ ប្រភេទចំណូល និង សមាមាត្របែងចែកត្រូវកំណត់ដោយច្បាប់ ឬ អនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៨.-**

មូលនិធិផ្ទេរពីថវិកាជាតិ រួមមានមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និង មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលពីថវិកាជាតិប្រចាំឆ្នាំ នូវមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និង មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ដែលត្រូវធ្វើឡើងជាដំណាក់កាលៗសម្រាប់ឆ្នាំនីមួយៗ ។

នីតិវិធី និង បែបបទនៃការផ្ទេរមូលនិធិពីថវិកាជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២៩.-**

មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ ជាមូលនិធិដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ :

- ដើម្បីគ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារជាកាតព្វកិច្ចមួយ ឬ ច្រើនដែលត្រូវបានផ្ទេរឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមការប្រគល់មុខងារ ឬ ការធ្វើប្រតិភូកម្មមុខងារ ឬ
- ដើម្បីបន្តគ្រប់គ្រង ឬ ចាត់ចែង និងអនុវត្តមុខងារជាជម្រើសមួយ ឬ ច្រើនដែលក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលធ្លាប់បានអនុវត្ត ឬ
- សំរាប់គោលបំណងជាកាតព្វកិច្ចមួយឬច្រើនដែលបានកំណត់ ។

ទម្រង់បែបបទ វិធាន និង លក្ខខណ្ឌនៃការផ្ទេរមូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៣០.-**

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ជាមូលនិធិដែលរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវប្រើប្រាស់ដើម្បី :

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារភារកិច្ចក្នុងការបង្កើត ការជំរុញ និង ការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន និង
- ជ្រើសរើស គ្រប់គ្រង ចាត់ចែង និង អនុវត្តមុខងារជាជម្រើសនានា ។

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិទទួលពីថវិកាជាតិប្រចាំឆ្នាំ នូវមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និងរូបមន្តប្រកបដោយតម្លាភាព ។

ទម្រង់បែបបទ វិធាន និង លក្ខខណ្ឌនៃការផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៣១.-**

រដ្ឋបង្កើតឲ្យមានមូលនិធិក្រុង ស្រុក ដែលមានគណនីដោយឡែកនៅធនាគារជាតិ ដើម្បីទទួលមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌពីថវិកាជាតិ និង ទទួលធនធានពីប្រភពផ្សេងៗទៀតសម្រាប់ជា

ប្រយោជន៍ដល់ថវិកាថ្នាក់រដ្ឋបាលក្រុង និង ស្រុក ។

មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌដែលត្រូវផ្ទេរពីថវិកាជាតិទៅមូលនិធិក្រុង ស្រុក ត្រូវធ្វើឡើងជាដំណាក់កាលៗក្នុងឆ្នាំនីមួយៗ តាមរូបមន្ត ឬ អត្រាជាក់លាក់ និង អាចប៉ាន់ប្រមាណបានសម្រាប់រយៈពេលមធ្យម។

ការវិភាជន៍ធនធានពីមូលនិធិក្រុង ស្រុកជូនទៅ រដ្ឋបាលថ្នាក់ក្រុង ស្រុកនីមួយៗ ត្រូវធ្វើឡើងប្រចាំឆ្នាំដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និង រូបមន្តប្រកបដោយតម្លាភាព ។

ការបង្កើត និង វិធានអនុវត្តរបស់មូលនិធិក្រុង ស្រុក ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៣២.-**

រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវចំណូលអំពីការអនុវត្តមុខងារជាភ្នាក់ងារ ក្នុងនាមក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៣.-**

រដ្ឋបាលថ្នាក់ក្រោមជាតិអាចទទួលបាននូវមុខងារជាភ្នាក់ងារក្នុងនាមរាជរដ្ឋាភិបាល ឬ ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយផ្អែកទៅតាមច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

រដ្ឋបាលថ្នាក់ក្រោមជាតិអាចពិភាក្សាឯកភាពគ្នាជាមួយក្រសួងស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រដ្ឋបាលថ្នាក់ជាតិ ដើម្បីទទួលអនុវត្តនូវកិច្ចការអ្វីមួយតាមរយៈកិច្ចសន្យា ឬ កិច្ចព្រមព្រៀងដែលក្នុងនោះបានកំណត់ច្បាស់អំពីកិច្ចការដែលត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត លទ្ធផលដែលត្រូវសម្រេច និង ប្រាក់កម្រៃដែលភ្នាក់ងារអនុវត្តត្រូវបានទទួល ។

ទម្រង់បែបបទ និង វិធាននៃការប្រើប្រាស់ថវិកាសម្រាប់អនុវត្តមុខងារជាភ្នាក់ងារខាងលើនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ផ្នែកទី ៣
## ការរៀបចំ និង ការអនុម័តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៣៤.-**

ផែនការយុទ្ធសាស្ត្រថវិកា និង គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយអភិបាលនៃគណៈអភិបាល និង អនុម័តដោយក្រុមប្រឹក្សា ទៅតាមនីតិវិធីដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ គឺជាកញ្ចប់ថវិកាមួយដែលត្រូវបញ្ជូនមកពិនិត្យអនុម័តដោយរដ្ឋសភា និង ព្រឹទ្ធសភា ក្នុងក្របខ័ណ្ឌនៃការពិនិត្យ និង អនុម័តច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។ ក្រោយពីច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវបានពិនិត្យ និង អនុម័តពីរដ្ឋសភា និងព្រឹទ្ធសភារួចហើយ កញ្ចប់ថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកទៅតាមក្រុមប្រឹក្សានីមួយៗ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣៥.-**

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំទៅតាមប្រតិទិនដូចខាងក្រោម ៖

**១- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ពីខែមីនា ដល់ខែឧសភា)**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំយុទ្ធសាស្ត្រថវិកាដល់គ្រប់ក្រសួងស្ថាប័ន អង្គភាពទាំងអស់ដើម្បីជូនដំណឹងដល់ក្រុមប្រឹក្សានីមួយៗនូវកម្មវិធី និង គម្រោងថវិកាក្នុងវិស័យរបស់ខ្លួន ដែលត្រូវអនុវត្តនៅដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ ។ ក្នុងនាមក្រុមប្រឹក្សា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ដោយឈរលើមូលដ្ឋានផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ រួចហើយដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ ពិភាក្សា និងអនុម័តហើយត្រូវផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបូកសរុបផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ១៥ ខែ ឧសភា ។

**២- ការរៀបចំកញ្ចប់ថវិកា (ពីខែមិថុនា ដល់ខែកញ្ញា)**

នៅសប្តាហ៍ទី ១ នៃ ខែ មិថុនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា ដោយបញ្ជាក់ពីទម្រង់បែបបទនីតិវិធីនៃការរៀបចំគម្រោងថវិកា និង ឯកសារពាក់ព័ន្ធដែលត្រូវភ្ជាប់ជាមួយ ហើយផ្ញើទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ។ អភិបាលនៃគណៈអភិបាលនីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំគម្រោងចំណូល ចំណាយថវិកាលំអិតរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានសារាចរណែនាំស្តីពីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និង អាទិភាពគោលនយោបាយនៃរដ្ឋបាលរបស់ខ្លួន ដោយដាក់បញ្ចូលនូវរាល់ប្រភពថវិកាទាំងអស់ដែលត្រូវអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងដោយអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដោយមានជំនួយពីប្រធានហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សា និង មន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលនៅថ្នាក់ក្រោមជាតិនីមួយៗក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវគម្រោងថវិកានេះដើម្បីប្រមូលយោបល់ចូលរួមរបស់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួចហើយត្រូវ

ពិនិត្យ និង រៀបចំឡើងវិញនូវគម្រោងថវិកានេះ ដើម្បីដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិភាក្សា និងអនុម័ត ក្នុងកិច្ចប្រជុំជាសាធារណៈយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែ មិថុនា ។

ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ក្រុង ស្រុក រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មឲ្យអភិបាលនៃគណៈអភិបាលខេត្តទទួលខុសត្រូវ ក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ បទបញ្ជា បែបបទ និង នីតិវិធីនានា ដែលកំណត់ដោយថ្នាក់ជាតិ ។ អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ក្នុងកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនអំពីដំណើរការគាំទ្របច្ចេកទេសនេះ ។

អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធានាថាមន្ត្រីនៃមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការបូកសរុបគម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុកក្នុងខេត្តរបស់ខ្លួនចូលក្នុងទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវគម្រោងថវិកា និង សេចក្តីអត្ថាធិប្បាយពន្យល់របស់ខេត្ត របស់ក្រុង របស់ស្រុក ហើយត្រូវផ្ញើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការប្រមូលផ្តុំបូកសរុបនូវគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំនីមួយៗ ។

ក្នុងអំឡុងខែសីហាទាំងមូល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យនីត្យានុកូលភាព និង បញ្ជាក់អនុលោមភាពលើថវិការបស់រាជធានី ថវិការបស់ខេត្ត ថវិការបស់ក្រុង និងថវិការបស់ស្រុក ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអាចធ្វើប្រតិភូកម្មនូវការពិនិត្យនីត្យានុកូលភាពទៅដល់អង្គភាពជំនាញរបស់ខ្លួន ឬ អាជ្ញាធរណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមការចាំបាច់ ។

ដំណើរការពិនិត្យនីត្យានុកូលភាព ត្រូវមានការចូលរួមពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង និង ស្រុកដែលតំណាងឲ្យក្រុមប្រឹក្សាជាម្ចាស់ថវិកា តំណាងក្រសួងមហាផ្ទៃ និង សមាស-ភាពដទៃទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ក្នុងដំណើរការពិនិត្យនីត្យានុកូល-ភាពនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់លើគោលការណ៍នៃការពិនិត្យនីត្យានុកូល-ភាព ដូចខាងក្រោម :

- គម្រោងថវិកាបានរៀបចំឡើងទៅតាមទម្រង់ចំណាត់ថ្នាក់ថវិកាបែបបទ និង នីតិវិធីដែលបានកំណត់
- មានការចូលរួមពីប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំថវិកា
- ការគ្រោងឥណទានទៅតាមគោលការណ៍ចំណាយចាំបាច់
- គម្រោងថវិកាត្រូវគ្រោងតាមលក្ខខណ្ឌដែលភ្ជាប់ទៅនឹងការប្រើប្រាស់ធនធានពីប្រភពផ្សេងៗដែលបានកំណត់ទុកជាមុន

- ជានាឲ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និង ចំណាយថវិកា
- មានការពិភាក្សាអនុម័តគម្រោងថវិកាក្នុងកិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ។

ក្នុងករណីដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលអំណាចប្រតិភូកម្មពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឃើញថាគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិណាមួយមិនស្របទៅនឹងគោលការណ៍ពិនិត្យនីត្យានុកូលភាពដូចបានចែងខាងលើ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អាជ្ញាធរដែលបានទទួលប្រតិភូកម្មអំណាចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសម្រេចកែសម្រួល និង ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំកែសម្រួលឡើងវិញទៅតាមនីតិវិធីជាធរមាន ។

**៣- ការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ពីខែតុលា ដល់ខែធ្នូ)**

នៅសប្តាហ៍ទី ១ នៃ ខែ តុលា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបញ្ជូនគម្រោងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ សម្រេច រួចដាក់ជូនរដ្ឋសភានៅសប្តាហ៍ទី ១ នៃ ខែ វិច្ឆិកា ដើម្បីពិនិត្យអនុម័តនិងដាក់ជូនព្រឹទ្ធសភានៅសប្តាហ៍ទី ១ នៃ ខែ ធ្នូ ដើម្បីសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តជាស្ថាពរមុនថ្ងៃទី ២៥ ខែ ធ្នូ ។

**មាត្រា ៣៦.-**

ប្រសិនបើគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រូវបានអនុម័តមុនថ្ងៃទី ០១ ខែ មករា នៃឆ្នាំសំរាប់ការិយបរិច្ឆេទដែលត្រូវអនុវត្តទេនោះ អភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិប្រមូលចំណូលតាមលក្ខខណ្ឌដែលបានអនុម័តដូចឆ្នាំមុន និង ធានាចំណាយប្រចាំខែ ក្នុងកម្រិត ១/១២ នៃថវិកាឆ្នាំមុន ។

## ផ្នែកទី ៤
## ការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៣៧.-**

ដើម្បីបម្រើឲ្យប្រតិបត្តិការចំណូល ចំណាយថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវបើកគណនីប្រាក់បញ្ញើនៅរតនាគារថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ។

**មាត្រា ៣៨.-**

ថវិការដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបានកែតម្រូវក្នុងអំឡុងឆ្នាំថវិកា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃលក្ខខណ្ឌសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលជះឥទ្ធិពលទៅលើការព្យាករណ៍ដំបូងនៃ

ចំណូល និង ចំណាយ ។ ការកែតម្រូវថវិកាត្រូវរៀបចំពិនិត្យ អនុម័ត និង បញ្ជាក់ទទួលស្គាល់តាម នីតិវិធី ដូចមានចែងនៅក្នុង មាត្រា ៣៥ នៃច្បាប់នេះ ។

**មាត្រា ៣៩.-**

ចលនាឥណទានផ្ទៃក្នុងនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងក្នុងលក្ខខណ្ឌដែល កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចធ្វើប្រតិភូកម្មដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការធ្វើនិយ័តកម្មឥណទានរបស់ខ្លួន ដើម្បីដោះស្រាយតម្រូវការក្នុងករណីចាំបាច់បន្ទាន់ ។

**មាត្រា ៤០.-**

ប្រភេទឥណទានថវិកានៃប្រភេទចំណាយមិនបានគ្រោងទុក អាចត្រូវបានប្រើប្រាស់សម្រាប់ ធានាចំពោះចំណាយទាំងឡាយណាដែលការវិភាជន៍មិនបានកំណត់ជាក់លាក់ នៅពេលឥណទាន ត្រូវបានអនុម័ត ឬ សម្រាប់ឥណទានបំពេញបន្ថែមជាគុណប្រយោជន៍ដល់ប្រភេទចំណាយផ្សេងៗ ទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

អភិបាលត្រូវស្នើសុំការអនុម័តពីក្រុមប្រឹក្សារបស់ខ្លួន ពេលមានតម្រូវការប្រើប្រាស់ឥណទាន ចំណាយថវិកាមិនបានគ្រោងទុក ។

**មាត្រា ៤១.-**

គម្រោង ឬ កម្មវិធីដែលអនុវត្តមិនទាន់ចប់នៅក្នុងឆ្នាំថវិកា ត្រូវបានដាក់បញ្ចូលដើម្បីបន្តអនុវត្ត ដោយលើកគម្រោងចំណាយទៅក្នុងថវិកានៃឆ្នាំបន្ទាប់ ។

**មាត្រា ៤២.-**

ក្នុងករណីការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឲ្យលេចចេញនូវឱនភាព រដ្ឋបាលថ្នាក់ ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីធានាតុល្យភាពថវិកាឡើងវិញ ។ នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ បានកើនលើសពី គម្រោងចំណូលប្រចាំឆ្នាំដែលបានគ្រោងទុក ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬ ធ្វើ និយ័តកម្មទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិនានា ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទៅតាមកម្រិតចំណូលលើសដែលបានបញ្ជិកា ។ នៅដំណាច់ឆ្នាំ ថវិកា អតិរេកថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកត់ត្រាចូលគណនីលទ្ធផលនៃធនាគារជាតិ ។

**មាត្រា ៤៣.-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាកម្មវត្ថុសំរាប់ធ្វើអធិការកិច្ច និង សវនកម្មរបស់ស្ថាប័នមានសមត្ថកិច្ច ។ គោលបំណងនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម គឺ សំដៅធានានូវតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព នៃប្រភពព័ត៌មានហិរញ្ញវត្ថុ និង ការវាយតម្លៃ នៃការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

របាយការណ៍អធិការកិច្ចហិរញ្ញវត្ថុ និង សវនកម្ម ដែលរួមមានបញ្ចូលនូវមតិយោបល់របស់ក្រុម ប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៤៤.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និង គណនេយ្យ ត្រូវប្រតិបត្តិតាមវិធានទាំងឡាយស្តីពីការត្រួតពិនិត្យ ហិរញ្ញវត្ថុ ការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ដែលត្រូវ កំណត់ដោយច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ៤៥.-**

ការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ជាជំពូកមួយនៃច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ។ គោរពតាមគោលការណ៍គណនេយ្យឯកភាព អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោម ជាតិ មានភារកិច្ចរៀបចំ និង ផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនូវរបាយការណ៍ស្តីពីការ អនុវត្តថវិកា និង ព័ត៌មានចាំបាច់ផ្សេងៗទៀតនៅពេលជំណាច់ឆ្នាំថវិកានីមួយៗ ។

**មាត្រា ៤៦.-**

នៅជំណាច់ឆ្នាំថវិកា អភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវធ្វើ ការផ្ទៀងផ្ទាត់គណនេយ្យរដ្ឋបាលរបស់ខ្លួនជាមួយនឹងគណនីគ្រប់គ្រងដោយគណនេយ្យករសាធារណៈ របស់រតនាគារ និង រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកា ព្រមទាំងព័ត៌មានចាំបាច់ផ្សេងៗទៀត ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និង អនុម័ត និង ផ្ញើជូនមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការបូកសរុប ជារបាយការណ៍រួមរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ រួចផ្ញើមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបូកសរុបជាសេចក្តីព្រាងនៃការទូទាត់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និង ដាក់បញ្ចូលទៅក្នុង ជំពូកមួយនៃសេចក្តីព្រាងច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋ ដែលត្រូវដាក់ទៅសុំការពិនិត្យ និង អនុម័ត ពីរដ្ឋសភា និង ព្រឹទ្ធសភា ។

# ជំពូកទី ៤
# ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា ៤៧.-**

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមានទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឲ្យ និង ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង ។ រដ្ឋផ្ទេរ និង ប្រគល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវសិទ្ធិកាន់កាប់ និង ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋមួយចំនួនដែលជាអចលនវត្ថុ ហើយស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗទៅតាមការកំណត់របស់រដ្ឋ ។

ការផ្ទេរ ប្រគល់ទ្រព្យសម្បត្តិរបស់រដ្ឋទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការផ្ទេរ ប្រគល់ ត្រូវបានប្រតិបត្តិក្នុងលក្ខណៈដែលអាចដកហូតយកមកវិញបាន ។

**មាត្រា ៤៨.-**

ការផ្ទេរទ្រព្យសម្បត្តិពីថ្នាក់ជាតិដើម្បីជាគុណប្រយោជន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ប្រើប្រាស់ជាសាធារណៈ ឬ សម្រាប់បំពេញនូវតម្រូវការនៃសេវាសាធារណៈ ត្រូវសមស្របទៅនឹងមុខងារ ដែលបានផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

**មាត្រា ៤៩.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវបានផ្ទេរប្រគល់ឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ប្រើប្រាស់ និង ទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវថែរក្សាការពារឲ្យបានគង់វង្ស និង គ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬ ផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ ។

**មាត្រា ៥០.-**

ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ជាកម្មសិទ្ធិផ្ទាល់ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រង និង ប្រើប្រាស់ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ នៅក្នុងក្របខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តដទៃទៀត ។

**មាត្រា ៥១.-**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋ ។

## ជំពូកទី ៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ៥២.-**

ក្នុងការអនុវត្តច្បាប់នេះដើម្បីឲ្យស្របទៅតាមតម្រូវការចាំបាច់ និង ផ្អែកតាមស្ថានភាព ជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួមទាំងរដ្ឋបាលឃុំ សង្កាត់ផង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិភាក្សាជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីស្នើឡើងនូវអនុក្រឹត្យ ឬ ចេញប្រកាសដោយឡែកៗសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ៥៣.-**

សមាជិកក្រុមប្រឹក្សា និង មន្ត្រីសាធារណៈគ្រប់ប្រភេទ និង គ្រប់ឋានៈដែលកំពុងបម្រើការងារ និង អ្នកដែលធ្លាប់បានបម្រើការងារកន្លងមក ហើយរកឃើញថាមិនបានគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងការអនុវត្តមុខងារ និង ភារកិច្ចរបស់ខ្លួនដែលបានប្រគល់ជូន នឹងត្រូវទទួលទណ្ឌកម្មខាងវិន័យទៅតាមច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ដែលមានជាធរមាន ដោយមិនគិតដល់ទោសព្រហ្មទណ្ឌ និង ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ព្រមទាំងត្រូវសងបង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិវិញ នូវរាល់តម្លៃបាត់បង់ខូចខាតទ្រព្យសម្បត្តិ ឬ ប្រាក់កាសសាធារណៈរួមទាំងការប្រាក់លើតម្លៃបាត់បង់ខូចខាត ដែលបង្កឡើងដោយកំហុសឆ្គងនេះ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៥៤.-**

ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលអនុវត្តកន្លងមកនៅមានសុពលភាពរហូតដល់មានច្បាប់ និង លិខិតបទដ្ឋានគតិយុត្តថ្មីមក

ជំនួសស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ច្បាប់នេះ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៥៥.-**

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ បទប្បញ្ញត្តិទាំងឡាយដែលជាវិសោធនកម្មនៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង និង បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣/ល. ១១០៦. ៥៩៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

២៤/៦

លេខ: ៥៥០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៤៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក ឈួន លីម

ជា

**ឧកញ៉ា**

៣រល.១១០៥.៤៦៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១

លេខៈ ៥៦០ ច.ល
ចម្លងចែក
ភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនអេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីសង្ឃ សប្បុរសជន និងមន្ត្រីរាជការ ចំនួន០៧រូប មាន ស្នាដៃល្អក្នុងការបម្រើជាតិមាតុភូមិ ព្រមទាំងជួយកសាងសមិទ្ធផលលើវិស័យព្រះពុទ្ធសាសនា នៅវត្តជលធីគីរីវ័ន្ត និងជួយអភិវឌ្ឍន៍ភូមិឃុំនានាក្នុងស្រុកស្រែអំបិល ខេត្តកោះកុង

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឯកឧត្តម គុក អាន

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

លោក ហេង ហ៊ុយ

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១-ព្រះតេជគុណ ហេង សំបូរ
២-លោកជំទាវ ស៊ីន ម៉ូយ

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-លោក ឌួន ស៊ីណា
២-វរសេនីយ៍ត្រី ម៉ា ធី អត្តលេខ ០១៥៥៤០
៣-លោក នៅ ធន្ធី

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៦.៥២៧

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៤៩៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យ៉ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
និងសប្បុរសជន ចំនួន ១០៨រូប បំពេញការងារសំខាន់ៗ ចូលរួមកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក/គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | សាន វិសាល | ១១-លោកជំទាវ | សុខ ខា |
| ២-ឯកឧត្តម | អ៊ឹង ផល្លារ | ១២-ឯកឧត្តម | ឧត្តមសេនីយ៍ទោ លី សុខម៉េង |
| ៣-ឯកឧត្តម | ហេង សារ៉ាវុធ | ១៣-ឯកឧត្តម | ឧត្តមសេនីយ៍ត្រី ប្រាក់ ប៊ុនថង |
| ៤-លោក | ថោង សារ៉ា | ១៤-ឯកឧត្តម | អ៊ុក សុគា |
| ៥-លោក | គួច សុភក្តិ | ១៥-លោក | ទូត វុត្ថា |
| ៦-លោក | ថោង ចំរើន | ១៦-លោក | កែវ ដារី |
| ៧-លោក | មាស ប្រសើរ | ១៧-លោកស្រី | យេល លក្ខិណា |
| ៨-លោកស្រី | ថោង គ្រីសស្តារីយ៉ា | ១៨-លោក | អ៊ុច ស៊ីម៉ារ៉ូ |
| ៩-លោក | ឈឹម សំណាង | ១៩-លោក | ឆាយ ឡេង |
| ១០-លោក | ធួន សេងកេង | ២០-លោក | ទេព ច័ន្ទសក្តាវឌ្ឍ |

ខ/គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

| | | | |
|---|---|---|---|
| ១-លោកជំទាវ | កែវ រស្មី | ៥-ឯកឧត្តម | ម៉ឹន សុខុន |
| ២-ឯកឧត្តម | អន ប៊ុណ្ណារឿន | ៦-ឯកឧត្តម | គួច ប៊ុលីវ៉ា |
| ៣-ឯកឧត្តម | ហាន់ វុទ្ធិ | ៧-ឯកឧត្តម | មាស ប៊ុល |
| ៤-លោកវរសេនីយ៍ឯក | សេង សាម៉ិឌី | ៨-ឯកឧត្តម | សា ផល្លី |

គ/គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម នួន សាមិន
២-ឯកឧត្តម ថាច់ ថង
៣-លោកជំទាវ គីម យ៉ាង

ឃ/គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម សេង ឈួន
២-ឯកឧត្តម ហ៊ុល សាភា
៣-ឯកឧត្តម ទេព ចាន់អុនវុធិរក្ស
៤-ឯកឧត្តម សុត រស្មី

ង/គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១-ឯកឧត្តម ឧកញ៉ា សុខ ផេង
២-ឯកឧត្តម វ៉ាន់ វ៉ាម៉ុន
៣-ឯកឧត្តម ធន់ សាម៉ន
៤-លោកជំទាវ តាន់ គីមឡាយ
៥-លោក ចាន់ សាហ៊ុត
៦-លោក គង់ សាឡន
៧-លោក លិន ញ៉ក់
៨-លោក ទន្នី ម៉ា
៩-លោក គង់ វណ្ណរដ្ឋ
១០-លោកស្រី អ៊ុង សុផល្លា
១១-លោកស្រី លី រ៉ូហ្សាមី
១២-លោក ពុធ ហាន
១៣-លោក អោក សំណាង
១៤-លោក កែវ សារុន
១៥-កញ្ញា គីម ណេង
១៦-លោក អ៊ិន ស៊ីវ៉ាន
១៧-លោក គន់ ប៊ុណ្ណា
១៨-លោក ជុំ សាមុំ
១៩-លោក សុខ ញ៉ា
២០-លោក អ៊ំរ៉ុង សុបិន្ត

ច/គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១-លោកជំទាវ កែវ បុប្ផា
២-ឯកឧត្តម សោម ទ្រី
៣-លោកស្រី ប៉ោ កូចសុខទៀង

ឆ/គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-លោក អ៊ុំ សេង
២-លោក គូ ជាឡុង
៣-លោក ប៉ោ ឡឿន
៤-លោក កង់ ជឿន
៥-លោក វង់ លាងហេង
៦-លោក ថង គីមសុន
៧-លោក អ៊ូ ណារីទ្ធ
៨-លោក ជុំ សាភិន
៩-លោក ជុំ សាភន
១៩-លោក យ៉ាំង ឆាយ
២០-លោក ជុំ សុភក្តិ
២១-លោកស្រី ជីន្នី ម៉ា
២២-លោកវរសេនីយ៍ទោ យិន សាន
២៣-អនុសេនីយ៍ឯក កោះ មករា
២៤-អនុសេនីយ៍ទោ គ្រុយ សុជាត្រា
២៥-អនុសេនីយ៍ទោ គុយ ផល្លា
២៦-អនុសេនីយ៍ទោ ប៉ាត សំណាត
២៧-អនុសេនីយ៍ទោ ចោង ម៉ារឌី

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១០-អនុសេនីយ៍ទោ ទូ ហុកស៊ីម
១១-អនុសេនីយ៍ទោ ប្រាជ្ញ សោភ័ណ្ណា
១២-លោក អ៊ឹម ភឺន
១៣-លោក អ៊ូ ពៅ
១៤-លោកវរសេនីយ៍ត្រី មាស ណុន
១៥-លោក អ៊ឹង ងួនសា
១៦-លោក សោម សំអឿន
១៧-លោក ប៉ាត់ អ៊ែល
១៨-លោក ឈរ សីហា
២៨-អនុសេនីយទោ សោម គិណាល់
២៩-អនុសេនីយ៍ត្រី ណុប នាង
៣០-អនុសេនីយ៍ត្រី ហ៊ិន ចន
៣១-លោក អ៊ុយ សុធឿន
៣២-លោក ចៅ ជីវ៉ា
៣៣-លោក ប៊ុស ចំរើន
៣៤-លោក អ៊ិន ស៊ីវន
៣៥-លោក ញ៉ឹក ស៊ីផុន

ជ/គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១-ឯកឧត្តម សុខ ផារិទ្ធ
២-ឯកឧត្តម គីម ពិសិដ្ឋ
៣-លោកស្រី លិន ដាម៉ា
៤-លោកស្រី អេឡឺ ម៉ា
៥-អនុសេនីយ៍ទោ លាស់ ស៊ីថា
៦-លោក ស្រ៊ុន សណ្តាប់

ឈ/គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១-លោក ស៊ូ ការ៉ូ
២-លោក សេង វ៉ា
៣-លោក សំ អ៊ឹមស្រ៊ុន
៤-លោក សួន ឌីណា
៥-លោក ញ៉ឹក ឈាងឡុង
៦-លោក អ៊ឹង សុខណា
៧-លោក លីវ ម៉ូរិទ្ធ
៨-លោកស្រី សំ សុខឃីម
៩-កញ្ញា សាត គន្ធា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤ល. ១១០៦. ៥២៤

លេខៈ ៥២៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥២០

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្ដម **មាស គឹមហេង** ជា **ទីប្រឹក្សា** ឯកឧត្ដម **ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

*ពរល.១១០៦.៥២៩*

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១*

**លេខ: ៤៩៧ ច.ល**
**សម្រាប់ចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី... ខែមិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៤២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**
**ទ្រង់ព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ ដែលមានគុណបំណាច់ ក្នុងការចូលរួមចំណែក
អភិវឌ្ឍមូលដ្ឋានឱ្យមានការរីកចម្រើនលើគ្រប់វិស័យក្នុងឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង

**នូវ**

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក **សៀង ស៊ុតថន** ៣-លោក **គោ សំអឿន**

២-លោក **ស៊ុន ហេង**

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ **មហាសេនា** :

១-លោក **ឆឹម ជាវ៉េត** ៥-លោក **វណ្ណ សុផល**

២-លោក **ញឹក ពេជ** ៦-លោក **គិត សុវត្ថិ**

៣-លោក **ជាល សុផល** ៧-លោក **ប៉ុក ប៊ុនរដ្ឋា**

៤-លោក **គីម ណារ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧ល.១១០៦.៥៣០

ធ្វើនៅព្រះបរមរាជវាំង ,ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៤៩៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**[illegible] ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥២២

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុណជាតិសាសនា រក្ខតខត្តិយា ខេមរជាតិរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ទីប្រឹក្សានិងមន្ត្រីរាជការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ១៨រូប
ដែលមានគុណបំណាច់ និងស្នាដៃល្អប្រសើរក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ

នូវ

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម កែវ សុខសិទ្ធិនី
២- លោក គិត ទ្រី
៣- លោក ញឹក សារ៉េត
៤- លោក ជា ជាតិ
៥- លោក មុយ ចាន់ពេញ
៦- លោក ឃុន ធុន្នី
៧- លោក អ៊ិច ឈុនស្រ៊ាង

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- លោក គឹម ឆៀង
២- លោក សន សុផល
៣- លោក ឆួច ឆៃ

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១- ឯកឧត្តម កើត ជឿន
២- លោក អ៊ា សារ៉េន
៣- លោក ថន ថា
៤- លោក ម៉ុន សំអុល
៥- លោក គង់ ធុត្ថា
៦- លោក ឆាន ធុត្ថា

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

- លោក ចូ ចន្ណា

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

- លោក សេង គឹមសាន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ការល.១១០៦.៥៣១*

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១*

លេខ: ៤៩៨ ច.ល
**ដើម្បីចម្លងចែក**
ភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

នស/រកត/០៦១១/៥២៣

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ចំនួន ០៥រូប
ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការបំពេញភារកិច្ច បម្រើជាតិមាតុភូមិ

នូវ

**គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម **អ៊ុង ជុនហួរ**
២- លោក **ង៉ែង សុទិដ្ឋារ៉ោ**
៣- លោក **ម៉ៅ ឡាំង**
៤- លោក **មាស សឿន**
៥- លោក **លី សារ៉េត**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៦.៥៣៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៥០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនអេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥២៤

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំនួន០៥រូប មានស្នាដៃល្អ
ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ លើការងារប្រៃសណីយ៍ និងទូរគមនាគមន៍

នូវ

## គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

| | | | |
|---|---|---|---|
| ១ | ឯកឧត្តម | **លឹម** | **គីមហេង** |
| ២ | ឯកឧត្តម | **ចែម** | **សទ្វារ** |
| ៣ | ឯកឧត្តម | **ម៉ូវ** | **ចរិយា** |
| ៤ | លោកស្រី | **ឡេ** | **ម៉ាយគៀង** |
| ៥ | លោក | **អៀង** | **ស្រេង** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង.ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១*

៣រល.១១០៦.៥៣៣

លេខៈ ៤៩៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ទ្រង់ព្រះរាជទាន

តែងតាំង

ឯកឧត្តម ខេង ច័ន្ទា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៦.៥៣៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៤៨៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ប្រគេនចំពោះ

ព្រះភិក្ខុ វណ្ណា សម្បត្តិ

ព្រះចៅអធិការវត្តបុទុមសិរីសែនមង្គល មានស្នាព្រះហស្ត និងព្រះគុណបំណាច់ក្នុងការអភិវឌ្ឍវិស័យព្រះពុទ្ធសាសនា
នៅក្នុងវត្តបុទុមសិរីសែនមង្គល សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរ.ល.១១០៦.៥៣៥

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៥០០ ច.ល
បានឃើញ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី... ខែមិថុនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
ប៉ុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥២៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ១៥រូប ដែលបានជួយកសាង សមិទ្ធផលនានា លើវិស័យ
ព្រះពុទ្ធសាសនា និងសង្គម នៅវត្តវេឡុការាម សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល

នូវ

**ក-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | | | |
|---|---|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | **ផន ណារ៉ា** អត្តលេខ ០០០០៧៨ | ៣- | លោកជំទាវ | **ម៉ែន ចន្ធី ហ៊ុំ ប៊ុនហៀង** |
| ២- | លោកជំទាវ | **អៀង គុណ្ឌី ឈុន ស៊ីរុន** | | | |

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | | | |
|---|---|---|---|---|---|
| ១- | លោកជំទាវ | **គីម សុគិន ឡៀង សារុន** | ៤- | អ្នកស្រី | **ហួយ គីមសេង** |
| ២- | លោកជំទាវ | **កាន់ ប៊ុនថាំ ផន ណារ៉ា** | ៥- | លោកជំទាវ | **សែម យេម ឡុង មេង** |
| ៣- | អ្នកស្រី | **ឆុច ធានី** | ៦- | ឯកឧត្តម | **ឡុញ ចន្ទ្ធៈ** |

**គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

| | | | | | |
|---|---|---|---|---|---|
| ១- | អ្នកស្រី | **លុយ ស៊ីចាន់** | ៤- | លោក | **សាត គីមសាន** |
| ២- | អ្នកស្រី | **នូ ស៊ុទ្ធណា** | ៥- | លោក | **សឿន សារ៉ាត្ន** |
| ៣- | លោក | **ស៊ីរិត សន** | ៦- | លោក | **គុយ ផេង** |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៦.៥៣៦

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១

លេខ: ៤៩៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៥៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ០៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ **នខ ថៃ** ភេទប្រុស អាយុ ៦៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៣-២០០៣ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩១ ចុះថ្ងៃទី ១៤-៧-២០០៣ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២-ទណ្ឌិតឈ្មោះ **ខិន សាលុន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៧-១៩៩៧ ពីបទ ធ្វើមនុស្សឃាតគិតទុកជាមុន និងកាន់កាប់អាវុធហាមឃាត់ខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៩ ចុះថ្ងៃទី ០៣-១០-១៩៩៧ របស់សាលាដំបូងខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ **សេន សល់** ហៅ មាស ស៊ឹម ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១០-២០០០ ពីបទ ចោរកម្ម, ប្រើប្រាស់អាវុធហាមឃាត់ដោយខុសច្បាប់, ធ្វើមនុស្សឃាតដោយចេតនា និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ខ" ចុះថ្ងៃទី ២៤-៤-២០០១ របស់សាលាដំបូងខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ **គូ ថុល** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-៩-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "គ" ចុះថ្ងៃទី ០៧-៤-២០០៦ របស់សាលាដំបូងខេត្តតាកែវ ។

៥-ទណ្ឌិតឈ្មោះ **ពៅ ជា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៩-២០០៤ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ "ខ" ចុះថ្ងៃទី ០២-៦-២០០៥ របស់សាលាដំបូងខេត្តតាកែវ ។

៦-ទណ្ឌិតឈ្មោះ **សុទ្ធ ណារិន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-០២-២០០២ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ២០ "ខ" ចុះថ្ងៃទី ២៥-០២-២០១០ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ២** : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ២២ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ **អួន លីអេង** ហៅ ចំរើន ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី២៩-៥-២០០៥ ពីបទ សមគំនិតក្នុងអំពើរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ "ន" ចុះថ្ងៃទី១២-៦-២០០៦ របស់សាលាដំបូងខេត្តកណ្តាល ។

២-ទណ្ឌិតឈ្មោះ **សុខ ចន្ថា** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី [illegible]-២០០២ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ០៦-៣-២០០៣ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៣-ទណ្ឌិតឈ្មោះ **ទឹម ទី** ហៅ គ្រាន់ ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៩-២០០៦ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ "ក" ចុះថ្ងៃទី ២៦-១២-២០០៦ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៤-ទណ្ឌិតឈ្មោះ **សឿម សំអុល** ហៅ លាក់ ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៩-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៣ "គ" ចុះថ្ងៃទី ១០-៤-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៥-ទណ្ឌិតឈ្មោះ **ហៀ បារាំង** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៦-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ ចុះថ្ងៃទី ០៨-៩-២០០៥ របស់សាលាដំបូងខេត្តពោធិសាត់ ។

៦-ទណ្ឌិតឈ្មោះ **រិន តារ៉ា** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៩ ចុះថ្ងៃទី ២៦-០១-២០០៦ របស់សាលាដំបូងខេត្តពោធិសាត់ ។

៧-ទណ្ឌិតឈ្មោះ **ស្រេន ទី** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៩-២០០៦ ពីបទ សមគំនិតរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៧ "គ" ចុះថ្ងៃទី ២៧-១០-២០០៦ របស់សាលាដំបូងខេត្តតាកែវ ។

៨-ទណ្ឌិតឈ្មោះ **ហោខ ហូ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៧-២០០៥ ពីបទ អំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ២៦-០១-២០០៦ របស់សាលាដំបូងខេត្តកោះកុង ។

៩-ទណ្ឌិតឈ្មោះ **ចាន់ សុវណ្ណារ៉ុង** ភេទប្រុស អាយុ ១៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៨-២០០៣ ពីបទ រំលោភសេពសន្ថវៈលើកុមារី ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧៧ ចុះថ្ងៃទី ០៥-៩-២០០៧ របស់តុលាការកំពូល ។

១០-ទណ្ឌិតឈ្មោះ **ព្រុំ វាសនា** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី [illegible]២០០៦ ពីបទ រំលោភសេពសន្ថវៈលើកុមារី(គ)អាយុ ១៤ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី [illegible]-៧-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

១១-ទណ្ឌិតឈ្មោះ **នួន ដារ៉ា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៤-២០០៥ ពីបទ រំលោភសេពសន្ថវៈលើកុមារីអាយុ ០៦ឆ្នាំ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ "ឃ" ចុះថ្ងៃទី ១២-៨-២០០៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១២-ទណ្ឌិតឈ្មោះ **ខ៊ាន់ ថ** ភេទប្រុស អាយុ ៤៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៥-២០០៥ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ "ឃ" ចុះថ្ងៃទី ២៤-៧-២០០៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១៣-ទណ្ឌិតឈ្មោះ **សាគ់ យ៉ុំ** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៨-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ "ឃ" ចុះថ្ងៃទី ១៥-៦-២០០៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១៤-ទណ្ឌិតឈ្មោះ **ផ៉ែរ ឡេះ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-១១-២០០៥ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៨ "គ" ចុះថ្ងៃទី ១៩-០២-២០១០ របស់សាលាឧទ្ធរណ៍ ។

១៥-ទណ្ឌិតឈ្មោះ **ទី សេខ** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-១២-២០០៣ ពីបទ ជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ឈ" ចុះថ្ងៃទី ២៣-៣-២០០៤ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៦-ទណ្ឌិតឈ្មោះ **សុច ច័ន្ទបូរិន** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-០២-២០០៥ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៤ "ង" ចុះថ្ងៃទី ០៤-១១-២០១០ របស់សាលាឧទ្ធរណ៍ ។

១៧-ទណ្ឌិតឈ្មោះ **ទឹម សំឡា** ភេទស្រី អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-១០-២០០៤ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៣ "ជ" ចុះថ្ងៃទី ០១-៦-២០១០ របស់សាលាឧទ្ធរណ៍ ។

១៨-ទណ្ឌិតឈ្មោះ **នៃ នេខ** ភេទស្រី អាយុ ៤៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ...២០០៥ ពីបទ ចាប់ពង្រត់ និងជួញដូរមនុស្ស ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៩ "ក" ចុះថ្ងៃទី ២២-៥-២០០៥ របស់សាលាឧទ្ធរណ៍ ។

១៩-ទណ្ឌិតឈ្មោះ **សេង លីនដា** ភេទស្រី អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-១១-២០០៤ ពីបទ ជួញដូរមនុស្សឱ្យធ្វើពេស្យាចារ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១០ "ខ" ចុះថ្ងៃទី ០៥-៩-២០០៧ របស់សាលាឧទ្ធរណ៍ ។

២០-ទណ្ឌិតឈ្មោះ **ញ៉ែម ឡោម** ភេទស្រី អាយុ ៥៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-១១-២០០៤ ពីបទ ជួញដូរមនុស្សឱ្យធ្វើពេស្យាចារ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលដីកាលេខ ១១០ "ខ" ចុះថ្ងៃទី ០៥-៩-២០០៧ របស់សាលាឧទ្ធរណ៍ ។

២១-ទណ្ឌិតឈ្មោះ **គីម មិនយ៉្យូ** (KIM MIN GYU) ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៣-២០០៦ ពីបទ សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៨ ចុះថ្ងៃទី ២១-៤-២០១០ របស់តុលាការកំពូល ។

២២-ទណ្ឌិតឈ្មោះ **កាង ក្យុងអូ** (KANG KYONG O) ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៥-២០០៦ ពីបទ សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៨ ចុះថ្ងៃទី ២១-៤-២០១០ របស់តុលាការកំពូល ។

**មាត្រា ៣** : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ៦៨ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ **ឿន ចាន់ណា** ភេទស្រី អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៣-២០០៩ ពីបទ បង្ករបួសដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ "ក" ចុះថ្ងៃទី ២២-៣-១៩៩៦ របស់សាលាដំបូងខេត្តកណ្តាល ។

២-ទណ្ឌិតឈ្មោះ **ស្រស់ ចន្ថា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៧-២០០៨ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ស/ម" ចុះថ្ងៃទី ៣០-៦-២០០៩ របស់សាលាដំបូងខេត្តកណ្តាល ។

៣-ទណ្ឌិតឈ្មោះ **ឆ្លាំង ឆ្លោក** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-[illegible]-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ [illegible] ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ "ណ" ចុះថ្ងៃទី ១៩-៦-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

៤-ទណ្ឌិតឈ្មោះ **ជា ដារ៉ា** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-០១-២០០៩ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ២១ "យ" ចុះថ្ងៃទី ២៤-៧-២០០៩ របស់សាលាដំបូងខេត្តកណ្តាល ។

៥-ទណ្ឌិតឈ្មោះ **ឌី ហៃ** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៦-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ "យ" ចុះថ្ងៃទី ៣១-៧-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ។

៦-ទណ្ឌិតឈ្មោះ **ឈុន តណ្ណា** ហៅ អាឡេវ ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-១១-២០០៨ ពីបទ ប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ "ខ" ចុះថ្ងៃទី ០៩-៤-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៧-ទណ្ឌិតឈ្មោះ **អ៊ឹម សុ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-១១-២០០៨ ពីបទ ប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦ "ខ" ចុះថ្ងៃទី ០៩-៤-២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៨-ទណ្ឌិតឈ្មោះ **ទិន ភឿន** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៥-២០០៩ ពីបទ ប្រើប្រាស់ឧបករណ៍ឆក់ត្រី ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "ក" ចុះថ្ងៃទី ០៣-៨-២០០៩ របស់សាលាដំបូងខេត្តស្ទឹងត្រែង ។

៩-ទណ្ឌិតឈ្មោះ **រចំ ភន** ភេទប្រុស អាយុ ៥២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៩-២០០៨ ពីបទ បង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ "ក" ចុះថ្ងៃទី ០៥-១០-២០០៩ របស់សាលាដំបូងខេត្តស្ទឹងត្រែង ។

១០-ទណ្ឌិតឈ្មោះ **យិន យ៉ន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១២-២០០៧ ពីបទ អំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ខ" ចុះថ្ងៃទី ១៩-៥-២០០៩ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

១១-ទណ្ឌិតឈ្មោះ **ឈឹម រតនៈ** ហៅ សារ៉ាយ ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៦-២០០៧ ពីបទ គំរាមកំហែងជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ "ខ" ចុះថ្ងៃទី ២០-៨-២០០៧ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១២-ទណ្ឌិតឈ្មោះ **គង់ សៅ** ភេទប្រុស អាយុ ៤៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-២០០៩ ពីបទ កាប់រានដីព្រៃក្នុងដែនបម្រុងទុកអចិន្ត្រៃយ៍ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ "ក" ចុះថ្ងៃទី ០៨-១០-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ។

១៣-ទណ្ឌិតឈ្មោះ **អ៊ុំ គីម** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-០១-២០១០ ពីបទ អំពើចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ "ច" ចុះថ្ងៃទី ០២-៩-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ។

១៤-ទណ្ឌិតឈ្មោះ **ផាន់ ធឿន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៧-២០០៩ ពីបទ អំពើចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២ "ក" ចុះថ្ងៃទី ១២-៥-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ។

១៥-ទណ្ឌិតឈ្មោះ **ម៉ិល ចារាំង** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-០១-២០១០ ពីបទ បង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣២ "ក" ចុះថ្ងៃទី ០១-១០-២០១០ របស់សាលាដំបូងខេត្តកំពង់ធំ ។

១៦-ទណ្ឌិតឈ្មោះ **ប្រាក់ សុជាតិ** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៩-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤ "គ" ចុះថ្ងៃទី ២៥-៤-២០០៧ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៧-ទណ្ឌិតឈ្មោះ **រិទ្ធិ រ៉ែន** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-៣-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "គ" ចុះថ្ងៃទី ១២-៨-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៨-ទណ្ឌិតឈ្មោះ **ហ៊ិន សុផាន់ណា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៨-២០០៧ ពីបទ ប្លន់ (ចោរកម្មមានគ្នាច្រើននាក់) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៥ "ក" ចុះថ្ងៃទី ១១-៦-២០០៨ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៩-ទណ្ឌិតឈ្មោះ **តាត ផាត** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី [illegible]-២០០៧ ពីបទ ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ "ច" ចុះថ្ងៃទី ១៧-១២-២០០៧ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២០-ទណ្ឌិតឈ្មោះ **ឱ ទេរ៉ា** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-៨-២០០៧ ពីបទ ប្លន់ (លួចមានគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ "គ" ចុះថ្ងៃទី ០៩-១-២០០៩ របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

២១-ទណ្ឌិតឈ្មោះ **ស្ង រិទ្ធី** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-៣-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ "ខ" ចុះថ្ងៃទី ០១-៩-២០០៨ របស់សាលាដំបូងខេត្តតាកែវ ។

២២-ទណ្ឌិតឈ្មោះ **នួន ឃ្លី** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៣-២០០៧ ពីបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ និងប៉ុនប៉ងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ "ក" ចុះថ្ងៃទី ២០-៨-២០០៧ របស់សាលាដំបូងខេត្តតាកែវ ។

២៣-ទណ្ឌិតឈ្មោះ **ខ៉ែត បូរី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-១១-២០០៧ ពីបទ អំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ "ខ" ចុះថ្ងៃទី ០៧-៨-២០០៨ របស់សាលាដំបូងខេត្តកោះកុង ។

២៤-ទណ្ឌិតឈ្មោះ **ឡាន់ សុធា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-១១-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ "ក" ចុះថ្ងៃទី ១៥-៧-២០០៨ របស់សាលាដំបូងខេត្តតាកែវ ។

២៥-ទណ្ឌិតឈ្មោះ **គុំ យ៉ាន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៧-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១២ "ក" ចុះថ្ងៃទី ០៥-១២-២០០៦ របស់សាលាដំបូងខេត្តតាកែវ ។

២៦-ទណ្ឌិតឈ្មោះ **ស៊ិន សឿន** ភេទប្រុស អាយុ ៤៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៦-២០០៨ ពីបទ អំពើបង្ករបួសដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "គ" ចុះថ្ងៃទី ១១-០២-២០០៩ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២៧-ទណ្ឌិតឈ្មោះ **ល័ក្ខ សុជា** ហៅ មិន សុជា ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-១២-២០០៥ ពីបទ បង្ខាំងមនុស្សខុសច្បាប់ជំរិតទារប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ [illegible] "ច" ចុះថ្ងៃទី ០៨-១២-២០០៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២៨-ទណ្ឌិតឈ្មោះ **ឈៀង នុង** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-១០-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ០១ "ឃ" ចុះថ្ងៃទី ១១-០១-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

២៩-ទណ្ឌិតឈ្មោះ **លីម ចក់** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៨-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "ឃ" ចុះថ្ងៃទី ២២-១២-២០០៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣០-ទណ្ឌិតឈ្មោះ **កែម ឆុ** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៨-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ "ឃ" ចុះថ្ងៃទី ២២-១២-២០០៥ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣១-ទណ្ឌិតឈ្មោះ **គួន ត្រឹត** ហៅ គង់ ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាបខ្លួននៅថ្ងៃទី ១៩-១០-២០០៦ ពីបទ ប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "ឃ" ចុះថ្ងៃទី ២២-០២-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣២-ទណ្ឌិតឈ្មោះ **គីម ហួរ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ច" ចុះថ្ងៃទី ១៥-៥-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣៣-ទណ្ឌិតឈ្មោះ **អ៊ីម សារឿន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-០២-២០០៦ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ "ច" ចុះថ្ងៃទី ១០-៧-២០០៦ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៣៤-ទណ្ឌិតឈ្មោះ **ហេង តារម្យ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៦-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៦ "ក" ចុះថ្ងៃទី ១៦-១០-២០០៧ របស់សាលាឧទ្ធរណ៍ ។

៣៥-ទណ្ឌិតឈ្មោះ **តឹក ចាំផល** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី [illegible]-២០០៨ ពីបទ សញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ [illegible] ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៤ "ង" ចុះថ្ងៃទី ១២-៨-២០១០ របស់សាលា[illegible]ណ៍ ។

៣៦-ទណ្ឌិតឈ្មោះ **ខៀវ ពិសិដ្ឋដារ៉ា** ហៅ អៀន ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៥-២០០៧ ពីបទ ប៉ុនប៉ងមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ០៣ "ដ" ចុះថ្ងៃទី ២៧-០១-២០១០របស់សាលាឧទ្ធរណ៍ ។

៣៧-ទណ្ឌិតឈ្មោះ **ចាន់ សុភ័ក្ត្រ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៧-២០០៨ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៩៤ "ខ" ចុះថ្ងៃទី ៣០-៩-២០១០ របសសាលាឧទ្ធរណ៍ ។

៣៨-ទណ្ឌិតឈ្មោះ **នាយ សារឿម** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-១១-២០០៧ ពីបទ ប្លន់ (គាស់ទម្លុះទម្លាយ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៣ "គ" ចុះថ្ងៃទី ២៣-៨-២០១០ របស់សាលាឧទ្ធរណ៍ ។

៣៩-ទណ្ឌិតឈ្មោះ **ខិន សុជាតិ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១២-២០០៧ ពីបទ ប្លន់ (លួចមានគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ០៩ "ង" ចុះថ្ងៃទី ១៨-០២-២០១០ របស់សាលាឧទ្ធរណ៍ ។

៤០-ទណ្ឌិតឈ្មោះ **ម៉ុក ពិសី** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៣-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២២ ចុះថ្ងៃទី ១៧-១០-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤១-ទណ្ឌិតឈ្មោះ **រៀម រីណា** ហៅ ឌីណា ភេទស្រី អាយុ ៥០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៩-២០០៥ ពីបទ លក់ដូរមនុស្សសម្រាប់នាំឆ្លងដែន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤០ "ក" ចុះថ្ងៃទី ០៨-៤-២០០៩ របស់សាលាឧទ្ធរណ៍ ។

៤២-ទណ្ឌិតឈ្មោះ **ញ៉ុក ចណ្ណា** ភេទប្រុស អាយុ ៤៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៨-២០០៩ ពីបទ ក្លែងលិខិតសាធារណៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ (៣ ឆ្នាំ ទោសដាក់ពន្ធនាគារ និង២ ឆ្នាំ ទោសព្យួរធម្មតា ) តាមអំណាចសាលដីកាលេខ ០៤ "ឋ" ចុះថ្ងៃទី ២២-៦-២០១០ របស់សាលាឧទ្ធរណ៍ ។

៤៣-ទណ្ឌិតឈ្មោះ **ណាម យ៉ុងវ៉ូ** (NAM YONGWOO) ភេទប្រុស អាយុ ៥៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៧-២០០៩ ពីបទ ប្រើប្រាស់លិខិតសាធារណៈក្លែងក្លាយ ហើយត្រូវតុលាការ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ (៣ ឆ្នាំ ទោសដាក់ពន្ធនាគារ និង២ ឆ្នាំ ទោសព្យួរធម្មតា ) តាមអំណាចសាលដីកាលេខ ០៤ "ឋ" ចុះថ្ងៃទី ២២-៦-២០១០ របស់សាលាឧទ្ធរណ៍ ។

ROYAUME du CAMBODGE — LE SECRETARIAT du PALAIS ROYAL

៤៤-ទណ្ឌិតឈ្មោះ **ព្រុំ សុជាតិ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-១១-២០០៨ ពីបទ ប្លន់ (គាស់គូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ (ដាក់ពន្ធនាគារដោយអនុវត្តទោសចំនួន ៣ ឆ្នាំ និងព្យួរទោស ២ ឆ្នាំ សាកល្បង ៣ ឆ្នាំ) តាមអំណាចសាលដីកាលេខ ៣៤ "ញ" ចុះថ្ងៃទី ២០-៧-២០១០ របស់សាលាឧទ្ធរណ៍ ។

៤៥-ទណ្ឌិតឈ្មោះ **ហម សីហា** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៧-៣-២០០៨ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៦ "ក្រ១" ចុះថ្ងៃទី ២៥-៦-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៦-ទណ្ឌិតឈ្មោះ **ឯម ពន្លឺ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-១២-២០០៨ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩២ "ក្រ២" ចុះថ្ងៃទី ២២-៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៧-ទណ្ឌិតឈ្មោះ **ឆា វ៉ាដែន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-១២-២០០៨ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩២ "ក្រ២" ចុះថ្ងៃទី ២២-៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៨-ទណ្ឌិតឈ្មោះ **សុខ ខ៊ាន់លី** ហៅ គ្រេន ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-១១-២០០៦ ពីបទ ប្លន់ (លួចគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ "ប" ចុះថ្ងៃទី ២៧-៦-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៩-ទណ្ឌិតឈ្មោះ **គឹម តូរ៉ា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-៥-២០០៦ ពីបទ ប្លន់ (លួចគាស់យកម៉ាស៊ីនត្រជាក់) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ "ឆ" ចុះថ្ងៃទី ២៤-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥០-ទណ្ឌិតឈ្មោះ **ទ្រី ឫទ្ធីថា** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ...-២០០៧ ពីបទ ប្លន់ (លួចមានគ្នាច្រើន) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ "ក្រ២" ចុះថ្ងៃទី ០៩-០១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥១-ទណ្ឌិតឈ្មោះ **សុខ ថាវរិទ្ធិ** ហៅ តីល ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួន នៅថ្ងៃទី ០៦-០២-២០០៨ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៣ "ក្រ១" ចុះថ្ងៃទី ១៤-៨-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥២-ទណ្ឌិតឈ្មោះ **សុត្រ ចំរើន** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៥-២០០៩ ពីបទ ប្លន់ (គំរាមយកប្រាក់) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ "ក្រ១" ចុះថ្ងៃទី ០១-៣-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៣-ទណ្ឌិតឈ្មោះ **កែវ បញ្ញារិទ្ធិ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៦-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ "កបIII" ចុះថ្ងៃទី ១២-៣-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៤-ទណ្ឌិតឈ្មោះ **ស្រេង នាយ** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៣-២០០៧ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥ "ក្រ២" ចុះថ្ងៃទី ០២-៥-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៥-ទណ្ឌិតឈ្មោះ **ឆេព សារឿន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៩-២០០៩ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណាក់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣០ "ដ" ចុះថ្ងៃទី ១០-៣-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៦-ទណ្ឌិតឈ្មោះ **ហាក្ស តារុណា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-៦-២០០៩ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ២០ "ក្រ១" ចុះថ្ងៃទី ១៧-០២-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៧-ទណ្ឌិតឈ្មោះ **យិន សុខហាប់** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃ [illegible]៩-៨-២០០៩ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ [illegible] ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១០ "កប៤" ចុះថ្ងៃទី ០៥-០១-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥៨-ទណ្ឌិតឈ្មោះ **សេង មករា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១២-២០០៥ ពីបទ ប្លន់ (ម៉ូតូ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ២៤ "ឆ" ចុះថ្ងៃទី ០៣-៤-២០០៩ របស់សាលាឧទ្ធរណ៍ ។

៥៩-ទណ្ឌិតឈ្មោះ **មុំ រិទ្ធី** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៣-២០០៧ ពីបទ ប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ២៧ "ញ" ចុះថ្ងៃទី ១៩-៥-២០១០ របស់សាលាឧទ្ធរណ៍ ។

៦០-ទណ្ឌិតឈ្មោះ **ទូច សេរីវ៉ាដា** ហៅ គុល ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-០១-២០០៩ ពីបទ ប្លន់ (ម៉ូតូ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩២ "ក្រ៣" ចុះថ្ងៃទី ១៤-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៦១-ទណ្ឌិតឈ្មោះ **ឡុង ធៀនមាំ** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៥-២០០៩ ពីបទ ចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៩ "ឈ" ចុះថ្ងៃទី ១៧-៨-២០១០ របស់សាលាឧទ្ធរណ៍ ។

៦២-ទណ្ឌិតឈ្មោះ **ឡុង គីមរាន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១០-២០០៦ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ២០ "ឈ" ចុះថ្ងៃទី ២៨-៤-២០០៩ របស់សាលាឧទ្ធរណ៍ ។

៦៣-ទណ្ឌិតឈ្មោះ **ម៉ៅ ធឿន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៥-២០០៥ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៥ "ប" ចុះថ្ងៃទី ១៩-១២-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៦៤-ទណ្ឌិតឈ្មោះ **ឆាន់ សុផាន់ណារា** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៦-២០០៩ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ១១ "ក្រIVត" ចុះថ្ងៃទី ០២-៣-២០១១ របស់សាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៦៥-ទណ្ឌិតឈ្មោះ **ខ៉ែត មុនី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៦-២០០៩ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ១១ "ក្រIVត" ចុះថ្ងៃទី ០២-៣-២០១១ របស់សាលាឧទ្ធរណ៍ ។

៦៦-ទណ្ឌិតឈ្មោះ **ប៉ោ កុសល្យ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៦-២០០៩ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ១១ "ក្រIVត" ចុះថ្ងៃទី ០២-៣-២០១១ របស់សាលាឧទ្ធរណ៍ ។

៦៧ ទណ្ឌិតឈ្មោះ **សៀ ចណ្ណារដេត** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៦-២០០៩ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ១១ "ក្រIVត" ចុះថ្ងៃទី ០២-៣-២០១១ របស់សាលាឧទ្ធរណ៍ ។

៦៨-ទណ្ឌិតឈ្មោះ **សុខ ដារ៉ាទី** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៦-២០០៩ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ១១ "ក្រIVត" ចុះថ្ងៃទី ០២-៣-២០១១ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ៤** : ត្រូវលើកលែងទោសឲ្យទណ្ឌិតចំនួន ៣១ នាក់ ដែលបានខិតខំកែប្រែខ្លួនបាន ល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោម ៖

១-ទណ្ឌិតឈ្មោះ **ខន ណារិទ្ធ** ហៅ ណាំ ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅ ថ្ងៃទី ២៥-៩-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ "ង" ចុះថ្ងៃទី ០៦-៥-២០០៨ របស់សាលា ដំបូងខេត្តព្រះសីហនុ ។

២-ទណ្ឌិតឈ្មោះ **ខ៉ា ផុន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-៤-២០០៧ ពីបទ អំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ "ង" ចុះថ្ងៃទី ២៧-១២-២០០៧ របស់ សាលាដំបូងខេត្តកំពង់ធំ ។

៣-ទណ្ឌិតឈ្មោះ **ហ៊ីន ខន់** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ...២-២០០៧ ពីបទ អំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ "ឃ" ចុះថ្ងៃទី ០៨-៨-២០០៧ របស់សាលា ដំបូងខេត្តកំពង់ធំ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៤-ទណ្ឌិតឈ្មោះ **ពុធ ធឿន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-០២-២០០៧ ពីបទ អំពើប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧ "ខ" ចុះថ្ងៃទី ១០-៨-២០០៧ របស់សាលាដំបូងខេត្តកំពង់ធំ ។

៥-ទណ្ឌិតឈ្មោះ **មិត្ត តឿ** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-០២-២០០៧ ពីបទ អំពើប្លន់ និងប្រើប្រាស់អាវុធហាមឃាត់ដោយខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ "ង" ចុះថ្ងៃទី ០៤-៧-២០០៧ របស់សាលាដំបូងខេត្តកំពង់ធំ ។

៦-ទណ្ឌិតឈ្មោះ **យ៉ ខ៊ុន** ភេទប្រុស អាយុ ៥៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៣-២០០៥ ពីបទ អំពើធ្វើពាណិជ្ជកម្មប្រភេទសត្វក្នុងក្រុមជិតផុតពូជ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៩ "ក" ចុះថ្ងៃទី ៣១-៨-២០០៥ របស់សាលាដំបូងខេត្តកោះកុង ។

៧-ទណ្ឌិតឈ្មោះ **ជួន ឌី** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៩-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ "ឃ" ចុះថ្ងៃទី ១១-០១-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៨-ទណ្ឌិតឈ្មោះ **ទី ទ៉ាន់** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៩-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ "ឃ" ចុះថ្ងៃទី ១១-០១-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

៩-ទណ្ឌិតឈ្មោះ **ផុន គុយ** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៨-២០០៦ ពីបទ ប្លន់ទ្រព្យសម្បត្តិ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ "ច" ចុះថ្ងៃទី ១២-០១-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១០-ទណ្ឌិតឈ្មោះ **នូ ខឿ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៨-២០០៦ ពីបទ ប្លន់ទ្រព្យសម្បត្តិ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ "ច" ចុះថ្ងៃទី ១២-០១-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១១-ទណ្ឌិតឈ្មោះ **ស៊ុន សុភ័ក្រ** ភេទប្រុស អាយុ ២៤ ឆ្នាំត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-១១-២០០៦ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ "ក" ចុះថ្ងៃទី ១៩-៦-២០០៧ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

១២-ទណ្ឌិតឈ្មោះ **កេត អ៊ី** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-១០-២០០៨ ពីបទ សញ្ចារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត ៣ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៤ "ង" ចុះថ្ងៃទី ១២-៨-២០១០ របសសាលាឧទ្ធរណ៍ ។

១៣-ទណ្ឌិតឈ្មោះ **អ៊ុច តាំងអ៊ន** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៣-២០១០ ពីបទ បើកបរដោយបង្កឱ្យស្លាប់ដល់អ្នកដទៃដោយអចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៦៣ "ខ" ចុះថ្ងៃទី១២-៧-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៤-ទណ្ឌិតឈ្មោះ **ម៉ុន ធីដែន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៩-២០០៩ ពីបទ ទទួលផលចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៣ កប៣ "ដ" ចុះថ្ងៃទី ១១-៥-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៥-ទណ្ឌិតឈ្មោះ **គីម សំណាង** ហៅ ក្តុំ ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៦-២០០៨ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ "ក្រ៥" ចុះថ្ងៃទី ២៩-១២-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៦-ទណ្ឌិតឈ្មោះ **ផៃ សុផុន** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-៤-២០០៨ ពីបទ ប្លន់ (គាស់រោងចក្រលួចខោ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦១ "ក្រ៥" ចុះថ្ងៃទី ២១-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៧-ទណ្ឌិតឈ្មោះ **លីវ យ៉ុងហួ** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-១០-២០០៣ ពីបទ ជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥១ "ក" ចុះថ្ងៃទី ០៦-៨-២០០៨ របស់សាលាឧទ្ធរណ៍ ។

១៨-ទណ្ឌិតឈ្មោះ **ឡឹក រតន** ហៅ យឿង ទាំងឡាយ ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៧-០១-២០០២ ពីបទ ធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦២ "ង" ចុះថ្ងៃទី ០៩-៦-២០០៦ របស់សាលាឧទ្ធរណ៍ ។

១៩-ទណ្ឌិតឈ្មោះ **សាត សឿន** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី [illegible]-១២-២០០៤ ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៣ ចុះថ្ងៃទី [illegible]-៨-២០០៩ របស់តុលាការកំពូល ។

២០-ទណ្ឌិតឈ្មោះ **ក្រាហាំ ម៉ាក ខល័លីម** (GRAHAM MC CALLUM) ភេទប្រុស អាយុ ៥១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-១១-២០០៨ ពីបទ អំពើធ្វើអាជីវកម្មផ្លូវភេទ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត ២ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ៧៣ "ច" ចុះថ្ងៃទី ២១-៩-២០១០ របស់សាលាឧទ្ធរណ៍ ។

២១-ទណ្ឌិតឈ្មោះ **ម៉ៅ សុភា** ហៅ កុយ ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៨-២០០៧ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៧ "គ" ចុះថ្ងៃទី ២៩-៧-២០០៩ របស់សាលាឧទ្ធរណ៍ ។

២២-ទណ្ឌិតឈ្មោះ **ឆាង សុគន្ធ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-៥-២០០៥ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៧ "គ" ចុះថ្ងៃទី ២៨-១២-២០១០ របស់សាលាឧទ្ធរណ៍ ។

២៣-ទណ្ឌិតឈ្មោះ **ចាំង ថាន់ធី** ភេទស្រី អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-៩-២០០៧ ពីបទ ជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥០ "ង" ចុះថ្ងៃទី ៣១-១២-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៤-ទណ្ឌិតឈ្មោះ **លាង ហុក** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-៩-២០០៧ ពីបទ ជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៥០ "ង" ចុះថ្ងៃទី ៣១-១២-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៥-ទណ្ឌិតឈ្មោះ **ផាត ម៉ិនរ័ត្ន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៩-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៨ "ឈ" ចុះថ្ងៃទី ១៥-១០-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៦-ទណ្ឌិតឈ្មោះ **សុខ ស៊ីយ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០២-២០០៧ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ៦ ខែ តាមអំណាចសាលដីកាលេខ ១៥៧ "ខ" ចុះថ្ងៃទី ២០-១២-២០០៧ របស់សាលាឧទ្ធរណ៍ ។

២៧-ទណ្ឌិតឈ្មោះ **ស្រី ចំរើន** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-០១-២០០៧ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៧ "ជ" ចុះថ្ងៃទី ២៩-៥-២០០៨ របស់សាលាឧទ្ធរណ៍ ។

២៨-ទណ្ឌិតឈ្មោះ **អ៊ុំ ពិសិដ្ឋ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០២-២០០២ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៨ ចុះថ្ងៃទី ២៧-១២-២០០៦ របសតុលាការកំពូល ។

២៩-ទណ្ឌិតឈ្មោះ **ណាន ស្រួយ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៩-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៨ "ឈ" ចុះថ្ងៃទី ១៥-១០-២០០៩ របស់សាលាឧទ្ធរណ៍ ។

៣០-ទណ្ឌិតឈ្មោះ **ឆេត រដ្ឋមុនា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-១២-១៩៩៩ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៧ "គ" ចុះថ្ងៃទី ១៤-៥-២០០៣ របស់សាលាឧទ្ធរណ៍ ។

៣១-ទណ្ឌិតឈ្មោះ **សាត់ ស៊ុយ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-១១-២០០៧ ពីបទ ប្លន់ (ឆក់ទូរស័ព្ទតាមផ្លូវសាធារណៈមិនសម្រេច) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ៥៥ "ញ" ចុះថ្ងៃទី ០៤-៦-២០០៩ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ៥** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល. ១១០៦.៥៤០

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១

លេខៈ ៤៩៦ ច.ល

**ដើម្បីចម្លងចែក**

ភ្នំពេញ, ថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ២០១១

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ឋិនភេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យអនុបយោគ

## ទីតាំងទីស្នាក់ការក្រុមហ៊ុន កាំមីនតែល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគ

-តាមសំណើ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រា ១ :-**

ត្រូវបានធ្វើវិសោធនកម្មមាត្រា១ នៃអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគទីតាំងស្នាក់ការក្រុមហ៊ុន កាំមីនតែល ស្ថិតនៅកែងផ្លូវព្រះស៊ីសុវត្ថិ និងផ្លូវលេខ៨៧ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយកែតម្រូវទំហំដី ពី ១.៩០០ ម៉ែត្រក្រឡា មកទំហំ ៣.៩០០ ម៉ែត្រក្រឡា តាមតួលេខជាក់ស្តែង ដែលកត់ត្រានៅក្នុងសាលាកប័ត្រដី នៃបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**មាត្រា ២ :-**

រាល់ខ្លឹមសារទាំងឡាយណានៃអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនមានការកែតម្រូវនៅមានសុពលភាពអនុវត្ត ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា ៣ :-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន កាំមីនតែល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ..១២០..អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកា ចំនួន ៣០០ លានរៀល (បីរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ចំនួន ២៤០ លានរៀល និង មកជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ៦០ លានរៀល ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការជំបូងរបស់ គ្រឹះស្ថានសាធារណៈរដ្ឋបាល មូលនិធិជនពិការ (មជព) ក្នុងឆ្នាំ ២០១១។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
  **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..១២១..អនក្រ-បក

## អនុក្រឹត្យ

## ស្តីពី

## ការបញ្ចូលមណ្ឌលសភាពាណិជ្ជកម្ម ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប ជាមណ្ឌលសភាពាណិជ្ជកម្មតែមួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-អនុក្រឹត្យលេខ ៤៤ អនុក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តតាកែវ

-អនុក្រឹត្យលេខ ៥៩ អនុក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកែប

-អនុក្រឹត្យលេខ ៤៥ អនុក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកំពត

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**មាត្រា១.-** ដោយខេត្តតាកែវ និងខេត្តកែប ពុំមានលក្ខខណ្ឌសម្បត្តិគ្រប់គ្រាន់ ក្នុងការបង្កើតសភាពាណិជ្ជកម្មដោយខ្លួនឯងរបស់ខ្លួន និង ដោយយោងតាមមាត្រា១ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម រាជរដ្ឋាភិបាលសម្រេចបញ្ចូលសភាពាណិជ្ជកម្មខេត្តតាកែវ និងខេត្តកែប ទៅក្នុងមណ្ឌលសភាពាណិជ្ជកម្មខេត្តកំពត ។

**មាត្រា២.-** វិសាលភាពសភាពាណិជ្ជកម្មខេត្តកំពត ត្រូវបានលាតសន្ធឹងទូទាំងខេត្តកំពត ខេត្តតាកែវ និងខេត្តកែប ។

**មាត្រា៣.-** ទីតាំងការិយាល័យប្រតិបត្តិនៃមណ្ឌលសភាពាណិជ្ជកម្មខេត្តទាំងបីខាងលើ ត្រូវស្ថិតនៅទីរួមខេត្តកំពត ។

**មាត្រា៤.-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពត អភិបាលខេត្តតាកែវ អភិបាលខេត្តកែប ប្រធានសភាពាណិជ្ជកម្មកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-សាលារាជធានី-ខេត្ត
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២២..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបញ្ចូលមណ្ឌលសភាពាណិជ្ជកម្ម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តរតនគិរី ជាមណ្ឌលសភាពាណិជ្ជកម្មតែមួយ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-អនុក្រឹត្យលេខ ៤៩ អនុក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តក្រចេះ

-អនុក្រឹត្យលេខ ៥០ អនក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តស្ទឹងត្រែង

-អនុក្រឹត្យលេខ ៥១ អនក្រ-បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តរតនៈគិរី

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ស ម្រេ ច

**មាត្រា១.-** ដោយខេត្តស្ទឹងត្រែង និងខេត្តរតនៈគិរី ពុំមានលក្ខខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើត សភាពាណិជ្ជកម្មដោយឡែករបស់ខ្លួន និង ដោយយោងតាមមាត្រា១ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម រាជរដ្ឋាភិបាលសម្រេច បញ្ចូលសភាពាណិជ្ជកម្មខេត្តស្ទឹងត្រែង និងខេត្តរតនៈគិរី ទៅក្នុងមណ្ឌលសភាពាណិជ្ជកម្មខេត្តក្រចេះ ។

**មាត្រា២.-** វិសាលភាពសភាពាណិជ្ជកម្មខេត្តក្រចេះ ត្រូវបានលាតសន្ធឹងទូទាំងខេត្តក្រចេះ ខេត្តស្ទឹងត្រែង និង ខេត្តរតនៈគិរី ។

**មាត្រា៣.-** ទីតាំងការិយាល័យប្រតិបត្តិនៃមណ្ឌលសភាពាណិជ្ជកម្មខេត្តទាំងបីខាងលើ ត្រូវស្ថិតនៅទីរួម ខេត្តក្រចេះ ។

**មាត្រា៤.-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តក្រចេះ អភិបាលខេត្តស្ទឹងត្រែង អភិបាលខេត្តរតនៈគិរី ប្រធានសភាពាណិជ្ជកម្មកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-សាលារាជធានី-ខេត្ត
-សភាពាណិជ្ជកម្មកម្ពុជា
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៩០ អនក្រ.តត

# អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ឃុ ម៉ុនលី** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ជា**អភិបាលក្រុងស្វាយរៀង** នៃខេត្តស្វាយរៀង ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៦ ឆ្នាំ២០១១

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៧៩២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៣១ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១១ ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ដេន សុផល** ឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ១៤ ជាអភិបាលស្រុកកោះសូទិន នៃខេត្តកំពង់ចាម ជំនួសលោក **ច្រឹង គឹមស្រ៊ាន** ដែលបានចូលនិវត្តន៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៦៥៧. អនក្រ.បក**

# អនុក្រឹត្យ

**ស្តីពី**

**ការដំឡើងឋានន្តរសក្តិ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ **ហោ សារ៉ាង** អត្តលេខ ០០៨៧០៨ នាយ ការិយាល័យសោធននិវត្តន៍ ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ទោ **យស យុន** អត្តលេខ ០០៣៨៣៥ នាយ ការិយាល័យសន្តិសុខផ្ទៃក្នុង ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន

៣-វរសេនីយ៍ទោ **ជា អេងយ៉ុង** អត្តលេខ ០១២៣៩៥ នាយ ការិយាល័យព័ត៌មានទូទៅ ស្នងការដ្ឋានព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៤-វរសេនីយ៍ទោ **តាង តារី** អត្តលេខ ០៣៥១០៦ នាយ ការិយាល័យបំភ័ន្តអក្ខរៈ ស្នងការដ្ឋានផែនការប្រតិបត្តិការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៥-វរសេនីយ៍ទោ **ស៊ិន ស៊ីថា** អត្តលេខ ០០២១៨១ នាយ ការិយាល័យស្រាវជ្រាវប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ស្នងការដ្ឋានស្រាវជ្រាវនិងយុត្តិធម៌ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៦-វរសេនីយ៍ទោ **នាង សុជីវី** អត្តលេខ ០២៣៣២៧ នាយ ការិយាល័យស្រាវជ្រាវប្រឆាំងគ្រឿងញៀន ស្នងការដ្ឋានស្រាវជ្រាវនិងយុត្តិធម៌ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៧-វរសេនីយ៍ទោ **មាស ម៉ុណ្ណា** អត្តលេខ ០៣៥៩៨៦ ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៨-វរសេនីយ៍ទោ **តេង ចំរើន** អត្តលេខ ០០៩៦៥៩ ជំនួយការ ឯកឧត្តម មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

៩-វរសេនីយ៍ទោ **រៀល ពិសិដ្ឋ** អត្តលេខ ០១៨៦៧១ នាយ ការិយាល័យផែនការប្រតិបត្តិការ ស្នងការដ្ឋានផែនការប្រតិបត្តិការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១០-វរសេនីយ៍ទោ **ម៉ែន រ៉ា** អត្តលេខ ០០៤៧៣៣ មេបញ្ជាការរង បញ្ជាការដ្ឋានរដ្ឋបាល បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១១-វរសេនីយ៍ទោ **ចៅ ឃីន** អត្តលេខ ០២១៨៦៩ នាយ ការិយាល័យសុខាភិបាល ស្នងការដ្ឋានភស្តុភារ បច្ចេកទេស បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១២-វរសេនីយ៍ទោ **សុខ សាន្ត** អត្តលេខ ០០២៧១២ នាយ លេខាធិការដ្ឋាន ស្នងការដ្ឋានព័ត៌មាននិងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៣-វរសេនីយ៍ទោ **ខាត់ សុឃីម** អត្តលេខ ០០៣៣៩៦ ជំនួយការ ឯកឧត្តម មេបញ្ជាការ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៤-វរសេនីយ៍ទោ **លីវ ណារ៉ា** អត្តលេខ ០២៣៨៤១ នាយករង សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៥-វរសេនីយ៍ទោ **សោម ស្រៀង** អត្តលេខ ០០៥២០០ នាយករង សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៦-វរសេនីយ៍ទោ **ឡូ គឹមលីន** អត្តលេខ ០០២៦៤៨ នាយករង សាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៧-វរសេនីយ៍ទោ **សែ ឧុទ្ធី** អត្តលេខ ១៣៨១៧៧ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តស្វាយរៀង

១៨-វរសេនីយ៍ទោ **យ៉េន សុខអៀង** អត្តលេខ ០០៥១៨៣ មេបញ្ជាការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តប៉ៃលិន

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩៣.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាម ដូចខាងក្រោម៖

១-ឧត្តមសេនីយ៍ទោ **ឡោ លីផុង** អត្តលេខ ០០០២១៤ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ទោ **ឌី ម៉ុនឆួច** អត្តលេខ ០១៣៧៧៣ ជា អគ្គលេខាធិការរង ក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ទោ **ម៉ម សុផាត** អត្តលេខ ០០០១៦៤ ជា អគ្គលេខាធិការរង ក្រសួងការពារជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឧត្តមសេនីយ៍ទោ **នេព ចំរើន** អត្តលេខ ០០០២១៥ ជា អគ្គលេខាធិការរង ក្រសួងការពារជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឧត្តមសេនីយ៍ទោ **សោម សុធា** អត្តលេខ ០០០២៤៣ ជា អគ្គនាយករង អគ្គនាយកដ្ឋាន ភស្តុភារហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន

៦-ឧត្តមសេនីយ៍ទោ **គង់ សាលី** អត្តលេខ ០០០២៥៥ ជា អគ្គនាយករង អគ្គនាយកដ្ឋាន ភស្តុភារហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន

៧-ឧត្តមសេនីយ៍ទោ **លី សុវណ្ណា** អត្តលេខ ០០០៧៣៧ ជា អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន

៨-ឧត្តមសេនីយ៍ទោ **ឡុច សុវណ្ណារិទ្ធ** អត្តលេខ ០១៧៣៩៤ ជា អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា បន្ថែមលើមុខងារបច្ចុប្បន្ន

៩-ឧត្តមសេនីយ៍ទោ **សៅ សារឿន** អត្តលេខ ០០១៤៦៦ ជា អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា បន្ថែមលើមុខងារបច្ចុប្បន្ន

១០-ឧត្តមសេនីយ៍ត្រី **គង់ សារី** អត្តលេខ ០០០៥៣៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

១១-ឧត្តមសេនីយ៍ត្រី **សោម សុវណ្ណា** អត្តលេខ ០០១៩៥៩ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

១២-ឧត្តមសេនីយ៍ត្រី **សំឆន សុគន្ធា** អត្តលេខ ០៤៣៥១៥ ជា នាយក នាយកដ្ឋានតំកល់ឯកសារ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ

១៣-ឧត្តមសេនីយ៍ត្រី **គីម យឿន** អត្តលេខ ០០១៨២៤ ជា អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៩៤ . អនក្រ .បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរសក្តិ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ **សោម ហួច** អត្តលេខ ០១៩១៨៤ មេបញ្ជាការរង កងពលតូចអន្តរាគមន៍លេខ៥ និងជាមេបញ្ជាការវរសេនាតូច២៥៣ កងពលធំអន្តរាគមន៍លេខ២ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ទោ **សន ម៉ាន់** អត្តលេខ ០១០០៧២ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៤២ និងជាមេបញ្ជាការវរសេនាតូច៤២១ យោធភូមិភាគទី៤

៣-វរសេនីយ៍ទោ **ឈឹម យ៉ឿន** អត្តលេខ ០០៣៦៣០ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៤២ និងជាមេបញ្ជាការវរសេនាតូច៤២២ យោធភូមិភាគទី៤

៤-វរសេនីយ៍ទោ **សៀង សុខ** អត្តលេខ ០០១២៦៣ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៨២ និងជាមេបញ្ជាការវរសេនាតូច៤២៣ យោធភូមិភាគទី៤

៥-វរសេនីយ៍ទោ **ហ៊ុយ ផាន់** អត្តលេខ ០០១២៦២ មេបញ្ជាការរង កងពលតូចថ្មើរជើងលេខ៨២ និងជាមេបញ្ជាការវរសេនាតូច៤២៤ យោធភូមិភាគទី៤

៦-វរសេនីយ៍ទោ **សេង ធារិន** អត្តលេខ ០៤៥៨៣៨ មេបញ្ជាការរង និងជានាយសេនាធិការ កងពលតូចថ្មើរជើងលេខ៥១ យោធភូមិភាគទី៥

៧-វរសេនីយ៍ទោ **អ៊ុង សំអាត** អត្តលេខ ០០៩៧៨៦ មេបញ្ជាការរង និងជានាយសេនាធិការ វរសេនាធំលេខ៤២ យោធភូមិភាគទី១

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៦៩៥ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម ÷

១-លោកវរសេនីយ៍ទោ **ឆេន ឈួត** អត្តលេខ ០២៨៩៧

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៨៦ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ របស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិលោកស្រី **សោម សួគ៌ា** ពីឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ៨ និងតែងតាំងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** [illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ. ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **សួន គឹមសាន់** អត្តលេខ ០២២៤៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ ថិបឌិន្ទ ជូនអស់លោកជាសប្បុរសជន ដែលមានគុណបំណាច់ក្នុងការរួមចំណែកកសាង និងអភិវឌ្ឍនៅមូលដ្ឋានក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១- លោក **ឆុន សុវត្ថិ**

២- លោក **សិលា សៅភិន**

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៨៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ១២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងអប់រំនៅ**វត្តពិជ័យឧត្តុង្គ** ហៅ( វត្តកំពង់បាយ) ស្ថិតនៅក្នុងសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ដែលមានរាយនាមដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៨ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **លឹម ផាន់ឆារៈ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៥២០ ដុល្លារ |
| ២-លោក | **គុប ស៊ីម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៣១០ ដុល្លារ |
| ៣-លោក | **ឈុន ហេង** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ៤-លោក | **នាក់ យិតថូ** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ៥-លោក | **មុយ ទុង** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១០.១៥០ ដុល្លារ |
| ៦-លោក | **សុខ ទិបុល** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៧-លោក | **ឃ្លាង លី** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៨-លោកស្រី | **ខឹន ខូនឡាយ** | សប្បុរសជនខ្មែររស់នៅប្រទេសបារាំង | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :**

| | | | |
|---|---|---|---|
| ១-លោក | **ម៉ី នួច** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ៥.៣០០ ដុល្លារ |
| ២-លោក | **តូ កុកយាន** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ៥.១០០ ដុល្លារ |
| ៣-លោក | **ណុប សុផល** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ៥.០០០ ដុល្លារ |

**គ. មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន**

| | | | |
|---|---|---|---|
| លោក | **ឃួន ឆន** | សប្បុរសជននៅខេត្តកំពត | ថវិកាចំនួន ១.០០០ ដុល្លារ |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៧០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ផ្តល់ជូនមន្ត្រីរាជការ និង សប្បុរសជនចំនួន ០៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅ**វត្តពិជ័យឧត្តុង្គ** ហៅ (វត្តកំពង់បាយ) ស្ថិតនៅក្នុងសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ដែលមានរាយនាមដូចខាងក្រោម :

១-លោក **គិត សុធារី** ជំនួយការអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ

២-លោកអនុសេនីយ៍ត្រី **តូ សុវណ្ណី** មន្ត្រីនគរបាលច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ អត្តលេខ ៣៣១០០

៣-លោកអនុសេនីយ៍ត្រី **ទុំ ដល្លី** មន្ត្រីនគរបាលច្រកទ្វារព្រំដែនអន្តរជាតិក្អមសំណរ អត្តលេខ ៤៤៥១

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ផ្តល់ជូនលោកឧត្តមសេនីយ៍ត្រី **តាត់ សុភាព** អត្តលេខ ០០១៥៦០ នាយករងនាយកដ្ឋានសំភារៈបច្ចេកទេស ក្រសួងការពារជាតិ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់ និង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍នៅ នៅ**វត្តពិជ័យឧត្តុង្គ** ហៅ (វត្តកំពង់បាយ) ស្ថិតនៅក្នុងសង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត **ចំណាយអស់ថវិកាសរុបចំនួន ៣៩.០០០ ដុល្លារ** ។

**មាត្រា ២ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកំពត និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧០២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **រស់ វណ្ណា** សប្បុរសជននៅខេត្តកំពង់ចាម ដែលបានបរិច្ចាគថវិកា ចំនួន ១២.៣០៨ ដុល្លារអាមេរិក ក្នុងការជួយកសាងសមិទ្ធផលនានា នៅវត្តខ្វិតធំ វត្តស្មែង និងវត្តត្រពាំងអំពិល ស្ថិតក្នុងឃុំខ្វិតធំ និងឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម សម្រេចបានលទ្ធផលល្អប្រសើរ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៧៣ . សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ

* * * * * * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១**: បង្កើតគណៈកម្មការសម្រាប់រៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន លើកទី១៦ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលនឹងប្រារព្ធធ្វើនៅទីក្រុង ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១២ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **គាត ឈន់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោកជំទាវ **នាង ច័ន្ទថាណា** | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **វង្សី វិស្សុត** | អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- តំណាងក្រសួងមហាផ្ទៃ | | សមាជិក |

៦- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៧-តំណាងក្រសួងព័ត៌មាន សមាជិក

៨- តំណាងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក

៩- ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការ

**ប្រការ២**: គណៈកម្មការរៀបចំកិច្ចប្រជុំនេះមានភារកិច្ចដូចតទៅ៖

ក- រៀបចំកម្មវិធីប្រជុំ និងពិធីការឲ្យបានសមស្រប

ខ- រៀបចំគម្រោងចំណាយសម្រាប់កិច្ចប្រជុំខាងលើ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល

គ- សម្របសម្រួល រៀបចំការពារសន្តិសុខជូនគណៈប្រតិភូ និងសមាជិកអង្គប្រជុំឲ្យមានសុវត្ថិភាព

ឃ- សម្របសម្រួល និងចាត់ចែងការធ្វើដំណើរទេសចរណ៍ជូនគណៈប្រតិភូក្រោយកិច្ចប្រជុំ តាមកម្មវិធីដែលបានគ្រោងទុក

ច- សម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយពីកិច្ចប្រជុំនេះ។

**ប្រការ៣**: ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិអញ្ជើញមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំដើម្បីពិភាក្សា និងដោះស្រាយការងារដែលចាំបាច់។

**ប្រការ៤**: ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងៗ តាមការចាំបាច់។

**ប្រការ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង និង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៤.សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៩៩៦/១៥ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

## សម្រេច

**ប្រការ ១:** ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២. ឯកឧត្តម **កាន់ ម៉ន** | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. ឯកឧត្តម **ពិត ចំណាន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៤. ឯកឧត្តម **អ៊ុក សុជាតិ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៥. ឯកឧត្តម **ទី តាយី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តម **ស៊ឹម វណ្ណា** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **យុន ឈុន្នី** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |

| | | |
|---|---|---|
| ៨. ឯកឧត្តម **ឡៅ ហ៊ីម** | នាយកប្រតិបត្តិ នៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល | សមាជិក |
| ៩. ឯកឧត្តម **ស៊ុំ សុផាន** | អគ្គលេខាធិការរងនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | សមាជិក |
| ១០. លោក **អាន គឹមអៀង** | ប្រធានសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា | សមាជិក |
| ១១. លោក **ហ៊ើព្រ៉ាល់ ហ៊ុម្ពាឌី** | នាយកសាលាសណ្ឋាគារ និងទេសចរណ៍ប៉ូល ឌុយហ្វ្រីល | សមាជិក |
| ១២. លោក **ពិន សារពេជ្រ** | នាយកគ្រប់គ្រងកម្មវិធីនៃអង្គការដើម្បីភាពញញឹមនៃកុមារ | សមាជិក |
| ១៣. លោក **លុះ ម៉េង** | ប្រធានសមាគមសណ្ឋាគារកម្ពុជា | សមាជិក |

**ប្រការ ២:** សមាជិកនៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍នេះមានភារកិច្ចអនុវត្តការងារទៅតាមការតម្រង់ទិស នៃអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និងប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៥៣ សហវ ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សំរាប់ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញក្រឹត្យលេខ ២៨/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១១

## សម្រេច :

**ប្រការ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១១ ត្រូវប្រមូលចាប់ពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១១ រហូតដល់ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១ ។

**ប្រការ២.-** ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១១ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត) ព្រមទាំងបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ច នូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០ ដើម្បីជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសំរាប់ឆ្នាំ២០១០ រួចហើយ ។

**ប្រការ៣.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណា ពុំមានបង្កាន់ដៃពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ២០១០ ទេនោះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវបង់ប្រាក់ពន្ធសំរាប់ឆ្នាំ២០១០ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១១ លើកលែងតែទោចក្រយានយន្តប៉ុណ្ណោះ ដែលពុំចាំបាច់ឱ្យម្ចាស់បង្ហាញបង្កាន់ដៃបង់ពន្ធឡើយ គឺគ្រាន់តែទិញប័ណ្ណបង់ពន្ធទោចក្រយានយន្តយកទៅបិទនឹងទោចក្រយានយន្តរបស់ខ្លួនជាការស្រេច ។ ក្នុងករណីទោចក្រយានយន្តណាមួយគ្មានបិទប័ណ្ណបង់ពន្ធ ត្រូវចាត់ទុកថាទោចក្រយានយន្តនោះមិនទាន់បានបង់ពន្ធនៅឡើយ ។

**ប្រការ៤.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសំរាប់ឆ្នាំ២០១០ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសំរាប់ឆ្នាំ២០១០ រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ នៃទីកន្លែងដែលយានយន្តនោះបានបង់ពន្ធសំរាប់ឆ្នាំ២០១០ ។

**ប្រការ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយ ។

**ប្រការ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះនេះ ត្រូវបានលើកលែងចំពោះ :

- រថយន្តពិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ។
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ របស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧.-** ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗ ត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងប័ណ្ណបង់ពន្ធមួយសន្លឹក សំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយយានយន្តសំរាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច និងទុកជាឯកសារសំរាប់បង់ពន្ធឆ្នាំ២០១២ ។

**ប្រការ៨.-** សំរាប់ឆ្នាំ២០១១ ប័ណ្ណបង់ពន្ធដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម :

**១.ប័ណ្ណរាងរង្វង់មូល :**

នៅផ្នែកខាងលើនៃប័ណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**"។ ខាងក្រោមអក្សរព្រះរាជាណាចក្រកម្ពុជា មានអក្សរ "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១១**"។ ផ្នែកកណ្តាលប័ណ្ណមានបោះពុម្ព Hologram រូបហង្សមានរស្មីប្រាំពីរពណ៌។ នៅកន្ទុយហង្សមាន Bar code ដោយអមជាមួយនូវលេខរៀងរាខ្ទង់របស់ប័ណ្ណនីមួយៗ។ ផ្នែកខាងក្រោមមានបោះពុម្ពអក្សរ "**ប័ណ្ណបង់ពន្ធរថយន្ត**" ឬ "**ប័ណ្ណបង់ពន្ធត្រាក់ទ័រ**" និងទឹកប្រាក់ពន្ធតាមប្រភេទប័ណ្ណព្រមទាំងមានកំរងក្បូរស្រូវទ្រពីក្រោមតាមរចនាបថអង្គរ។ នៅផ្នែកខាងក្រោយនៃសន្លឹកប័ណ្ណមានបង្កប់បន្ទះឈីប (Chip) សំរាប់ការពារការក្លែងបន្លំប័ណ្ណ (លើកលែងប័ណ្ណបង់ពន្ធត្រាក់ទ័រ)។

ប័ណ្ណរាងរង្វង់មូលនេះ មាន**១៥**ពណ៌គឺ :

- **ប័ណ្ណពណ៌ត្រួយចេកខ្ចីប្រើសំរាប់** ត្រាក់ទ័រមានកម្លាំង ៣៥ សេះ **(៣០.០០០រៀល)**
- **ប័ណ្ណពណ៌ខៀវប្រើសំរាប់** ត្រាក់ទ័រមានកម្លាំង ៦៥ សេះ **(៤០.០០០រៀល)**
- **ប័ណ្ណពណ៌ខៀវខ្ចីប្រើសំរាប់** ត្រាក់ទ័រមានកម្លាំង ៨២ សេះ **(៥០.០០០រៀល)**
- **ប័ណ្ណពណ៌លឿងទុំ និងពណ៌ស្វាយ(៨០.០០០រៀល) ប្រើសំរាប់ :**
  - \+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ
- **ប័ណ្ណពណ៌លឿងទុំ(១០០.០០០រៀល) ប្រើសំរាប់ :**
  - \+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  - \+ រថយន្តទេសចរណ៍កម្លាំងលើសពី១៥០០ ស.ម³ដល់២០០០ស.ម³ គិតពីឆ្នាំផលិតលើស៥ឆ្នាំ
- **ប័ណ្ណពណ៌ផ្កាឈូក (១៥០.០០០រៀល) ប្រើសំរាប់ :**
  - \+ រថយន្តដឹកទំនិញដល់ ៣ តោន
  - \+ រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  - \+រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី១៥០០ស.ម³ដល់២០០០ស.ម³គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- **ប័ណ្ណពណ៌ខៀវខ្ចី(២០០.០០០រៀល) ប្រើសំរាប់ :**
  - \+ រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- **ប័ណ្ណពណ៌ស្វាយ (២៥០.០០០រៀល)ប្រើសំរាប់ :**
  - \+ រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន
  - \+ រ៉ឺម៉កសណ្តោង ដល់ ១០ តោន
  - \+ រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥
- **ប័ណ្ណពណ៌បៃតង និងពណ៌ត្រួយចេក (៣៦០.០០០រៀល) ប្រើសំរាប់ :**
  - \+រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី២០០០ស.ម³ដល់ ២៥០០ស.ម³ គិតពីឆ្នាំផលិតលើសពី៥ឆ្នាំ

- **ប័ណ្ណពណ៌បៃតង(៨៥០.០០០រៀល) ប្រើសំរាប់ :**
    + រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន
    + រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន
- **បណ្ណពណ៌ខៀវខ្ចី និងពណ៌ត្រួយចេក (៥០០.០០០រៀល) ប្រើសំរាប់ :**
    + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២០០០ ស.ម³ ដល់ ២៩០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- **បណ្ណពណ៌ផ្កាឈូក និងពណ៌ត្រួយចេក (៧៥០.០០០រៀល) ប្រើសំរាប់ :**
    + រថយន្តដឹកទំនិញលើសពី ២០ តោន
    + រ៉ឺម៉កសណ្តោងលើសពី ២០ តោន
- **បណ្ណពណ៌បៃតង និងពណ៌លឿងទុំ (១.២០០.០០០រៀល) ប្រើសំរាប់ :**
    + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម³ ដល់ ៤០០០ ស.ម³ គិតពីឆ្នាំផលិតលើស ៥ឆ្នាំ
- **បណ្ណពណ៌ផ្កាឈូក និងពណ៌ត្រួយចេក (១.៦០០.០០០រៀល)ប្រើសំរាប់ :**
    + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម³ ដល់ ៤០០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- **បណ្ណពណ៌ស្វាយ និងពណ៌ខៀវខ្ចី (២.០០០.០០០រៀល)ប្រើសំរាប់ :**
    + រថយន្តទេសចរណ៍កម្លាំងលើសពី ៤០០០ ស.ម³ ឡើងទៅ

**២. <u>បណ្ណរាងពងក្រពើ</u> :**

នៅផ្នែកខាងលើនៃប័ណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**"។ ខាងក្រោមអក្សរព្រះរាជាណាចក្រកម្ពុជាមានអក្សរ "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១១**"។ ផ្នែកកណ្តាលប័ណ្ណមានបោះពុម្ព Hologramរូបហង្សមានរស្មីប្រាំពីរពណ៌។ នៅកន្ទុយហង្សមាន Bar code ដោយអមជាមួយនូវលេខរៀងពន្ធរបស់ប័ណ្ណនីមួយៗ។ ផ្នែកខាងក្រោមមានបោះពុម្ពអក្សរ "**ប័ណ្ណបង់ពន្ធលើយានយន្ត**" ទ្រពីក្រោមដោយកំរងកួរស្រូវតាមរចនាបថអង្គរ និងលេខតំណាងទឹកប្រាក់ពន្ធតាមប្រភេទប័ណ្ណនៅផ្នែកខាងក្រោម។

បណ្ណរាងពងក្រពើនេះ មាន**៥**ពណ៌គឺ :

- **បណ្ណពណ៌លឿង (៣.០០០រៀល) ប្រើសំរាប់ :**
    + ទោចក្រយានយន្តទំហំពិសស្តុង ដល់ ៧០ សម³
- **បណ្ណពណ៌ខៀវ (៤.៥០០រៀល) ប្រើសំរាប់ :**
    + ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ៧០ សម³ ទៅ ១២៥ សម³
- **បណ្ណពណ៌បៃតង (៧.៥០០រៀល) ប្រើសំរាប់ :**
    + ទោចក្រយានយន្តមានទំហំពិសស្តុងលើសពី ១២៥ សម³ ឡើងទៅ ដែលមានទឹកប្រាក់ពន្ធចំនួន ៧.៥០០ រៀល

- **ប័ណ្ណពណ៌ផ្កាឈូក (១៥.០០០រៀល) ប្រើសំរាប់ :**

+ ត្រីចក្រយានយន្ត និងម៉ូតូរ៉ឺម៉កដឹកទំនិញ ឬអ្នកដំណើរ (បំពាក់ដោយម៉ាស៊ីនម៉ូតូ) ដែលមានទឹកប្រាក់ពន្ធ ចំនួន ១៥.០០០ រៀល

**៣. ប័ណ្ណរាងចតុកោណស្មើជ្រុង:**

នៅផ្នែកខាងលើនៃប័ណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**"។ ខាងក្រោមអក្សរព្រះរាជាណាចក្រកម្ពុជាមានអក្សរ "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១១**"។ ផ្នែកកណ្តាលប័ណ្ណមានបោះពុម្ព Hologramរូបហង្សមានស្មើប្រាំពីរពណ៌។ នៅកន្ទុយហង្សមាន Bar code ដោយអមជាមួយនូវលេខរៀងរាងរបស់ប័ណ្ណនីមួយៗ។ ផ្នែកខាងក្រោមមានបោះពុម្ពអក្សរ"**ប័ណ្ណបង់ពន្ធជលយាន**"ទៅពីក្រោមដោយកំរងផ្កាស្រូវតាមរចនាបថអង្គរ។

ប័ណ្ណរាងចតុកោណស្មើជ្រុងនេះមាន៣ពណ៌គឺ :

- **ប័ណ្ណពណ៌ផ្កាឈូក ប្រើសំរាប់ :**

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០៛ ដល់ ៧០.០០០៛

- **ប័ណ្ណពណ៌បៃតង ប្រើសំរាប់ :**

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០៛ ដល់ ៥០០.០០០៛

- **ប័ណ្ណពណ៌លឿងទុំ ប្រើសំរាប់ :**

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០៛ ដល់ ១.២០០.០០០៛

**ប្រការ៩.-** ដោយឡែក សំរាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉ក-សណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុប ដែលរួមមានទម្ងន់រថយន្តទទេ និងទម្ងន់ផ្ទុក (ទំនិញ-មនុស្ស) ។

-ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត និង រថយន្តកែច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវកំណត់ជារថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០,០០០៛

- រឺរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០.០០០៛
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០.០០០៛
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០៛ និង
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០,០០០៛ ។

**ប្រការ១០.-** យានយន្តគ្រប់ប្រភេទ ដែលមានប័ណ្ណសំគាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០ ហើយបានលក់ទៅឱ្យអ្នកផ្សេង ក្នុងករណីនេះម្ចាស់យានយន្តត្រូវបង់ពន្ធសំរាប់ឆ្នាំ២០១០ និងបង់ប្រាក់ពិន័យស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធសំរាប់ឆ្នាំ២០១១ ។

**ប្រការ១១.-** មធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែកមួយ និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសនោះប្រកាសបង់ពន្ធលើប្រាក់ចំណេញអាករលើតម្លៃបន្ថែម... ជារៀងរាល់ខែ ។

**ប្រការ១២.-** ចាប់ពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១១ នេះតទៅ អង្គភាពពន្ធដារត្រូវធ្វើការត្រួតពិនិត្យ និងដាក់ពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណាដែលមិនបានបង់ពន្ធសំរាប់ឆ្នាំ២០១១ ដូចបានកំណត់ក្នុងប្រការ១ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់អោយធ្វើចរាចរនៅក្រោយថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១១ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នកលក់អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬប័ណ្ណសំគាល់យានយន្តថតចំលង... ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធ បន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សំរាប់ឆ្នាំ២០១១ នេះ ។

**ប្រការ១៣.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

គាត ឈន់

***កន្លែងទទួល :***

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ សហវ

## តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់
## ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ

( តារាងឧបសម្ព័ន្ធទី I )

ភ្ជាប់ជាមួយប្រកាសលេខ.[illegible]....សហវ.ប្រក ចុះថ្ងៃទី[illegible]..ខែ.[illegible].ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ឯកតា : រៀល**

| **ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ** | **អត្រាប្រាក់ពន្ធសម្រាប់១ឆ្នាំ ក្នុងមួយគ្រឿង** | |
|---|---|---|
| **. រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)] :** | | |
| + ដល់ ៣ តោន | 150 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| **. រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ) :** | | |
| + ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី | 150 000 | |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦ កៅអី ដល់ ២៥ កៅអី | 200 000 | |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី | 250 000 | |
| រថយន្តទេសចរណ៍ គ្រប់ប្រភេទ | **គិតពីឆ្នាំផលិត** | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| + ទំហំស៊ីឡាំងដល់ ១៥០០ ស.ម$^{៣}$ ( ដល់ ១.៥ លីត្រ) | 100 000 | 80 000 |
| + ទំហំស៊ីឡាំងលើសពី១៥០០ស.ម$^{៣}$ដល់ ២០០០ស.ម$^{៣}$ (លើសពី ១.៥ ដល់ ២.០លីត្រ) | 150 000 | 100 000 |
| + ទំហំស៊ីឡាំងលើសពី ២០០០ស.ម$^{៣}$ ដល់ ២៨០០ស.ម$^{៣}$(លើសពី ២.០ ដល់២.៨លីត្រ) | 500 000 | 360 000 |
| + ទំហំស៊ីឡាំងលើសពី ២៨០០ ស.ម$^{៣}$ ដល់ ៤០០០ ស.ម$^{៣}$(លើសពី២.៨ ដល់៤.០លីត្រ) | 1 600 000 | 1 200 000 |
| + ទំហំស៊ីឡាំងលើសពី ៤០០០ ស.ម$^{៣}$ ឡើងទៅ (លើសពី ៤.០លីត្រ) | 2 000 000 | |

| | |
|---|---|
| - ត្រាក់ទ័រកម្លាំង ៣៩ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 30 000 |
| - ត្រាក់ទ័រកម្លាំង ៦៩ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 40 000 |
| - ត្រាក់ទ័រកម្លាំង ៨២ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 50 000 |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម$^{៣}$ | 3 000 |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ៧០ ស.ម$^{៣}$ ដល់ ១២៥ ស.ម$^{៣}$ | 4 500 |
| ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម$^{៣}$ ឡើងទៅ | 7 500 |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬ អ្នកដំណើរ | 15 000 |
| **ជលយាន ឬជលយានយន្ត ផ្លូវទន្លេ** : | |
| - **ជលយានដឹកទំនិញ** : | |
| + ដល់ ៣ តោន | 50 000 |
| + លើសពី ៣ តោន ដល់ ១០ តោន | 100 000 |
| + លើសពី ១០ តោន ដល់ ២០ តោន | 200 000 |
| + លើសពី ២០ តោន | 300 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 200 000 |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | 300 000 |
| - កប៉ាល់សណ្តោងមានកម្លាំងដល់ ៥០ សេះ | 20 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 30 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 50 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ | 60 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ | 180 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២៥០ សេះ ឡើងទៅ | 300 000 |
| - កាណូតនេសាទមានកម្លាំងដល់ ៥០ សេះ | 10 000 |
| - កាណូតនេសាទមានកម្លាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 20 000 |
| - កាណូតនេសាទមានកម្លាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 30 000 |
| - ទូកម៉ាស៊ីនចំហៀង " ជើងបង្កង " | 10 000 |
| - អូប័រមានកម្លាំងដល់ ២៥ សេះ | 150 000 |
| - អូប័រមានកម្លាំងលើសពី ២៥ សេះ ដល់ ៤០ សេះ | 200 000 |
| - អូប័រមានកម្លាំងលើសពី ៤០ សេះ ដល់ ៨០ សេះ | 300 000 |
| - អូប័រមានកម្លាំងលើសពី ៨០ សេះ ដល់ ២០០ សេះ | 400 000 |
| - អូប័រមានកម្លាំងលើសពី ២០០ សេះ ឡើងទៅ | 500 000 |

| | |
|---|---|
| **ជលយាន ឬជលយានយន្ត ផ្លូវសមុទ្រ :** | |
| - ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - ទូកដឹកអ្នកដំណើរបណ្តោយពី ២១ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 150 000 |
| - ទូកដឹកទំនិញដល់ ១០០ តោន | 200 000 |
| - ទូកនេសាទដែលមានកម្លាំងសេះដល់ ៩ សេះ | 10 000 |
| - ទូកនេសាទដែលមានកម្លាំងសេះពី ១០ សេះ ដល់ ២០ សេះ | 15 000 |
| - ទូកនេសាទដែលមានកម្លាំងសេះលើសពី ២០ សេះ ដល់ ៤០ សេះ | 25 000 |
| - ទូកនេសាទដែលមានកម្លាំងសេះលើសពី ៤០ សេះ ដល់ ៨០ សេះ | 50 000 |
| - ទូកនេសាទដែលមានកម្លាំងសេះលើសពី ៨០ សេះ ដល់ ១៥០ សេះ | 70 000 |
| - ទូកនេសាទដែលមានកម្លាំងសេះលើសពី ១៥០ សេះ ឡើងទៅ | 100 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២ សេះ | 10 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ១២ សេះ ដល់ ៥០ សេះ | 20 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ៥០ សេះ ឡើងទៅ | 50 000 |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន | 300 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន | 750 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ | 1 200 000 |
| - កប៉ាល់នេសាទមានកម្លាំងដល់ ១៥០ សេះ | 300 000 |
| - កប៉ាល់នេសាទមានកម្លាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ | 400 000 |
| - កប៉ាល់នេសាទមានកម្លាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 600 000 |
| - កប៉ាល់នេសាទមានកម្លាំងលើសពី ៥០០ សេះ ឡើងទៅ | 1 200 000 |
| - កប៉ាល់សណ្តោងមានកម្លាំងដល់ ២៥០ សេះ | 200 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 400 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ៥០០ សេះ ឡើងទៅ | 600 000 |

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ .................... សហវ.....

# ឧបសម្ព័ន្ធកំណត់ទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍

( តារាងឧបសម្ព័ន្ធទី II )

ភ្ជាប់ជាមួយប្រកាសលេខ ៣៥៣.. ប្រក.សហវ.ពដ ចុះថ្ងៃទី ០៧.. ខែ មិថុនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

| ល.រ | រថយន្តទេសចរណ៍ដែលប្រើប្រាស់ថាមពលសាំង ឬ ម៉ាស៊ូត | ទំហំស៊ីឡាំងគិតជា ស.ម³ · CC · | ទំហំស៊ីឡាំងគិតជាលីត្រ (១លីត្រ=១០០០ស.ម³) | ប្រាក់ពន្ធត្រូវបង់ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ | គិតពីឆ្នាំផលិត លើសពី ៥ឆ្នាំ | |
| ១ | រថយន្តទេសចរណ៍ | ដល់ ១ ៥០០ស.ម³ | ដល់ ១.៥ | ១០០ ០០០ រៀល | ៨០ ០០០ រៀល | |
| ២ | រថយន្តទេសចរណ៍ | លើសពី ១ ៥០០ស.ម³ ដល់ ២០០០ ស.ម³ | លើស១.៥ ដល់ ២.០ | ១៥០ ០០០ រៀល | ១០០ ០០០ រៀល | |
| ៣ | រថយន្តទេសចរណ៍ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ ស.ម³ | លើស២.០ ដល់ ២.៩ | ៥០០ ០០០ រៀល | ៣៦០ ០០០ រៀល | |
| ៤ | រថយន្តទេសចរណ៍ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ ស.ម³ | លើសពី២.៩ ដល់ ៤.០ | ១ ៦០០ ០០០ រៀល | ១ ២០០ ០០០ រៀល | |
| ៥ | រថយន្តទេសចរណ៍ | លើសពី ៤ ០០០ស.ម³ ឡើងទៅ | លើសពី ៤.០ | ២ ០០០ ០០០ រៀល | | |

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០១១

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤២១ ឧរថ.ភរ -ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ៧៦៣ /១១ គ.វ.ក ចុះថ្ងៃទី២៦.០៤.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន សាញនិង ថេកស្តាយ ខប ចុះថ្ងៃទី២៨.០៤.២០១១

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន សាញនីង ថេកស្តាយ ខប តំណាង ដោយ លោក CHUNG, YANG-YU សញ្ជាតិចិន(តៃវ៉ាន់) អាយុ៣៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 132326459 ចុះថ្ងៃទី០៨.០៨.២០០១ មានអាសយដ្ឋានបច្ចុប្បន្ន៖ 7-F No. 70. Sec. 1 Kuan Fu Rd. San Chung City,Taipei Hsien Taiwan. ជាម្ចាស់រោងចក្រធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

-ផ្លាកឈ្មោះរោងចក្រ ៖ " *សាញនីង ថេកស្ទាយ ខប ( SHINING TEXTILE CORP. )* "

-ទីតាំងរោងចក្រ ៖ " *ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ* "

**ប្រការ២.** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

